**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Science Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការទទួលស្គាល់រដ្ឋ៖ ករណីកោះតៃវ៉ាន់

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **គង់ តាយសេង**
ភិក្ខុ **ម៉ម ម៉ាប់**

ណែនាំដោយ
បណ្ឌិត **យឹម គិរី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩
ឆ្នាំសរសេរសារណា ២០២៣

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Science Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការទទួលស្គាល់រដ្ឋ៖ ករណីកោះតៃវ៉ាន់

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **គង់ តាយសេង**
ភិក្ខុ **ម៉ម ម៉ាប់**

ណែនាំដោយ
បណ្ឌិត **ឃឹម គីរី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩
ឆ្នាំសរសេរសារណា ២០២៣

# **អំណះអំណាង**

យើងខ្ញុំឈ្មោះ **គង់ តាយសេង** និង **ម៉ម ម៉ាប់** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី២៣ ឆ្នាំសិក្សា ២០១៩-២០២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមធ្វើការអះអាងចំពោះខ្លឹមសារសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ ពិតជាកើតចេញពីគំនិតផ្ទាល់ខ្លួនរបស់យើងខ្ញុំ និងដោយបានការជួយជ្រោមជ្រែងពី **បណ្ឌិត ឃឹម គិរី** ទាំងឯកសារស្នារតី និងការជួយពន្យល់បង្ហាត់បង្ហាញ ដែលធ្វើឱ្យយើងខ្ញុំមាន ទុននៅក្នុងការសរសេរសារណានេះឡើង ដោយមិនមានការថតចម្លងសារណា ឬរបាយការណ៍ ឬនិក្ខេបបទ របស់អ្នកផ្សេងឡើយ។

ថ្ងៃអង្គារ ១៥កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៣

| **ហត្ថលេខា** | **ហត្ថលេខា** |
|---|---|
| លោក **គង់ តាយសេង** | ភិក្ខុ **ម៉ម ម៉ាប់** |

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **គង់ តាយសេខ** និង **ម៉ម ម៉ាច់** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៩-២០២៣។

## សូមលំឱនកាយសម្តែងនូវកតញ្ញូតាចំពោះ

លោកឪពុកអ្នកម្តាយ ដែលបានផ្តល់កំណើត បីបាច់ថែរក្សាឱ្យរស់ប្រកបដោយក្តីស្រលាញ់អប់រំទូន្មានប្រៀនប្រដៅប្រកបដោយទំនួលខុសត្រូវខ្ពស់បំផុត និងការជួយទំនុកបម្រុងគ្រប់បែបយ៉ាងដើម្បីឱ្យកូនទទួលបានការសិក្សាតាំងពីបឋមសិក្សា រហូតដល់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះប្រកបដោយសេចក្តីសមប្រកប និងជោគជ័យ។

**ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឱ្យពួកយើងខ្ញុំ បានសិក្សានៅសាកលវិទ្យាល័យនេះ និងបានបង្កនូវភាពងាយស្រួលដល់ការសិក្សាសម្រាប់និស្សិតគ្រប់រូប។

**បណ្ឌិត ឃឹម គីរី** ដែលបាន ចំណាយពេលវេលាដ៏មមាញឹក និងមានតម្លៃបំផុត ក្នុងការធ្វើជាសាស្ត្រាចារ្យណែនាំលើការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រមួយនេះ ព្រមទាំងការបង្ហាត់បង្ហាញ និងបង្កលក្ខណៈងាយស្រួលបំផុតក្នុងការសរសេរសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ។

ថ្នាក់ដឹកនាំ សាស្ត្រាចារ្យ សាស្ត្រាចារ្យរង សាស្ត្រាចារ្យជំនួយ លោក/លោកស្រី បុគ្គលិកសិក្សានៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដែលបានបង្ហាត់បង្រៀន និងបង្កភាពងាយស្រួលក្នុងដំណើរការសិក្សាតាំងពីដើមមក។

ក្រសួងស្ថាប័នពាក់ព័ន្ធ អ្នកនិពន្ធ ម្ចាស់ឯកសារ និងអ្នកស្រាវជ្រាវទាំងឡាយដែលបានចូលរួមចំណែកយ៉ាងសំខាន់សម្រាប់ពួកយើងធ្វើការស្រាវជ្រាវនិងសិក្សាកន្លងមក។

ជាចុងក្រោយ សូមប្រសិទ្ធពរជ័យជូនដល់ លោកអ្នកមានគុណ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង បណ្ឌិត សាស្ត្រាចារ្យ សាស្ត្រាចារ្យរង សាស្ត្រាចារ្យជំនួយ លោក/លោកស្រី និងបុគ្គលិកសិក្សាទាំងអស់ សូមឱ្យជួបតែសេចក្តីសុខ សេចក្តីសម្រើន សុខភាពល្អ កម្លាំងមាំមួន ជោគជ័យគ្រប់ភារកិច្ច និងទទួលបាននូវពុទ្ធិព្រឹទ្ធ ដូចបំណងប៉ងប្រាថ្នា និងឈ្នះអស់មារសត្រូវទាំងឡាយ។

សូមអ្នកមានគុណទាំងពីរ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង បណ្ឌិត សាស្ត្រាចារ្យ សាស្ត្រាចារ្យរង សាស្ត្រាចារ្យជំនួយ លោក/លោកស្រី បុគ្គលិកសិក្សា ទទួលការគោរពដឹងគុណពីយើងខ្ញុំទាំងពីររូប។

# អារម្ភកថា

ក្រោមការគាំទ្រ ជម្រុញ លើកទឹកចិត្ត និងជួយបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ ពីសំណាក់លោកឪពុកអ្នកម្ដាយ សាស្ត្រាចារ្យទាំងអស់ នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាពិសេស បណ្ឌិត ឃឹម គីរី ទីបំផុតសៀវភៅសារណាបញ្ចប់ការសិក្សា ក៏បានចាប់បដិសន្ធិឡើង។ សៀវភៅដែលមិត្តអ្នកអាន កំពុងតែកាន់នៅ នឹងដៃ គឺជាសមិទ្ធិផលថ្មីមួយ ដែលយើងខ្ញុំទាំងពីរ ជានិស្សិតផ្នែកនីតិសាស្ត្រ ថ្នាក់ L4B1 បានខិតខំប្រឹងប្រែងរួបរួមគ្នាបង្កើតឡើង ក្រោមប្រធានបទ «**ការទទួលស្គាល់រដ្ឋ៖ ករណីកោះតៃវ៉ាន់**»។ ដូចអ្វីដែលមិត្តទាំងអស់គ្នាធ្លាប់បានដឹង និងបានឮចមកហើយថា ភាពជារដ្ឋពេញលេញ ចាំបាច់ត្រូវមានការទទួលស្គាល់ ហើយចំពោះបញ្ហាកោះតៃវ៉ាន់ឯណោះវិញមានភាពមិនច្បាស់លាស់សូម្បីអ្នកសិក្សាស្រាវជ្រាវ ក៏ដូចជាភាគីកោះតៃវ៉ាន់ខ្លួនឯងផ្ទាល់ពុំច្បាស់លាស់អំពីតួនាទី ក៏ដូចជាភាពជារដ្ឋពេញលេញ ដែលសម្ដែងឡើងក្នុងបញ្ហាអន្តរជាតិ និងមានបញ្ហាប្រឈមចំពោះប្រវត្តិសាស្ត្ររបស់ខ្លួនជាមួយនិងប្រទេសចិន។ ម្យ៉ាងវិញទៀត មូលហេតុដែលយើងខ្ញុំទាំងពីរសម្រេចចិត្តជ្រើសរើសយក ប្រធានបទ «**ការទទួលស្គាល់រដ្ឋ៖ ករណីកោះតៃវ៉ាន់**» ដោយសារយើងខ្ញុំគិតថា ជាប្រធានបទមួយថ្មីសម្រាប់មិត្តនិស្សិត ក៏ដូចជាអ្នកសិក្សាជំនាន់ក្រោយៗ អាចធ្វើការសិក្សា និងស្រាវជ្រាវបន្ថែម អំពីការទទួលស្គាល់រដ្ឋ ក៏ដូចជាភាពជារដ្ឋពេញលេញ និងស្ថានភាពផ្សេងៗទៀតនៃរដ្ឋដទៃទៀត ឬបញ្ហានៃកោះតៃវ៉ាន់នេះ។ ទោះបីជាមានការខិតខំចងក្រងនូវសារណាដោយយកចិត្តទុកដាក់យ៉ាងណាក្តី ក៏យើងខ្ញុំនៅតែជឿជាក់ថា កំហុសនៅតែមាន ដោយសារតែយើងខ្ញុំដែលជាអ្នកសិក្សាស្រាវជ្រាវក្នុងការបង្កើតស្នាដៃ នៅមានភាពក្មេងខ្ចី។ ដូច្នេះហើយ ប្រសិនបើសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំមានកំហុសឆ្គងយ៉ាងណា សូម សាស្ត្រាចារ្យ សាស្ត្រាចារ្យរង សាស្ត្រាចារ្យជំនួយ លោក/លោកស្រី អ្នកស្រាវជ្រាវ និងមិត្តអ្នកអានទាំងអស់មេត្តាខន្តីអភ័យទោសដល់យើងខ្ញុំផង។ យើងខ្ញុំព្រមទទួលនូវរាល់ពាក្យពេជន៍ទាំងឡាយ ក្នុងន័យរិះគន់ដើម្បីស្ថាបនា ព្រោះយើងខ្ញុំតែងតែសង្ឃឹមជឿជាក់ថា សារណារបស់យើងខ្ញុំ នឹងអាចក្លាយជាប្រយោជន៍ដល់អ្នកសិក្សាជំនាន់ក្រោយ ប្រៀបដូចជាប្រទីបសម្រាប់បំភ្លឺដល់ការសិក្សា និងជាយានដើម្បីឆ្លងឱ្យដល់ត្រើយនៃបញ្ញាវន្ត។

ជាចុងក្រោយនេះ យើងខ្ញុំទាំងពីររូប សូមលើកដៃប្រណម្យសួងដល់វត្ថុសក្តិសិទ្ធិទាំងអស់នៅក្នុងលោកសូមគោរពជូនពរដល់លោកឪពុកអ្នកម្ដាយ សាស្ត្រាចារ្យ សាស្ត្រាចារ្យរង សាស្ត្រាចារ្យជំនួយ លោក/លោកស្រី នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ពិសេស **បណ្ឌិត ឃឹម គីរី** ក៏ដូចជាមិត្តអ្នកអានទាំងអស់ ឱ្យជួបតែពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

**១. លំនាំបញ្ហា** ........ ១

**២. ចំណោទបញ្ហា** ........ ៣

**៣. គោលបំណងនៃការស្រាវជ្រាវ** ........ ៣

**៤. ដែនកំណត់នៃការស្រាវជ្រាវ** ........ ៣

**៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ** ........ ៣

**៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ** ........ ៤

**១. ប្រមូលទិន្នន័យ** ........ ៤

**២. ការបកស្រាយ និង វិភាគ** ........ ៤

**៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ** ........ ៤

## ជំពូកទី១

## សញ្ញាណទូទៅនៃរដ្ឋ

**១.១ និយមន័យនៃរដ្ឋ** ........ ៦

**១.២ ធាតុផ្សំនៃរដ្ឋ** ........ ៨

១.២.១ ប្រជាពលរដ្ឋអចិន្ត្រៃយ៍ ........ ៨

១.២.២ ទឹកដីមួយជាកំណត់ ........ ១០

១.២.៣ រដ្ឋាភិបាល ........ ១៥

## ជំពូកទី២

## ការទទួលស្គាល់រដ្ឋ នៅក្នុងនីតិអន្តរជាតិ

**២.១ និយមន័យ និងមូលហេតុនៃការទទួលស្គាល់** ........ ១៨

**២.២ ប្រភេទ និងទម្រង់នៃការទទួលស្គាល់** ........ ២០

២.២.១ ការទទួលស្គាល់រដ្ឋ និងរដ្ឋាភិបាល ........ ២០

២.២.២ ការទទួលស្គាល់ក្រុមបះបោរ (Recognition of Belligerency) ........ ២២

២.២.៣ ការទទួលស្គាល់ តាមផ្លូវច្បាប់ និង តាមព្រឹត្តិន័យ ........ ២២

២.២.៤ ការទទួលស្គាល់ជា លាយលក្ខណ៍អក្សរ និងដោយស្ងៀមស្ងាត់ ........ ២៣

២.២.៥ ការទទួលស្គាល់មានលក្ខខណ្ឌ ........ ២៤

**២.៣ វិបាកផ្លូវច្បាប់នៃការទទួលស្គាល់រដ្ឋ** ........ ២៤

២.៣.១ វិបាកកម្រិតអន្តរជាតិនៃការទទួលស្គាល់ ............................................................. ២៤
២.៣.២ វិបាកកម្រិតជាតិនៃការទទួលស្គាល់ .................................................................. ២៥

**ជំពូកទី៣**

**ករណីកោះតៃវ៉ាន់**

**៣.១ ស្ថានភាពជាក់ស្តែង៖ កោះតៃវ៉ាន់** ............................................................. ២៦
៣.១.១ បញ្ហាប្រជាពលរដ្ឋ ............................................................................. ២៧
៣.១.២ បញ្ហារដ្ឋាភិបាល និង ទឹកដី ................................................................ ២៧
**៣.២ ការសិក្សាវិភាគ ចំណុចវិជ្ជមាន និងចំណុចអវិជ្ជមាន** ........................................... ២៩
៣.២.១ ចំណុចវិជ្ជមាន ................................................................................ ៣០
៣.២.២ ចំណុចអវិជ្ជមាន .............................................................................. ៣០
៣.២.២.១ សមត្ថភាពក្នុងការកសាងទំនាក់ទំនងជាមួយរដ្ឋដទៃ ........................................ ៣០
៣.២.២.២ ករណីនៃការទទួលស្គាល់សាធារណរដ្ឋប្រជាមានិតចិន ..................................... ៣១
៣.២.២.៣ ភាពអវិជ្ជមានដ៏ធំបំផុតនៃស្ថានភាពនយោបាយ ............................................ ៣២
**សេចក្តីសន្និដ្ឋាន** ............................................................................................ ៣៤
**អនុសាសន៍** .................................................................................................. ៣៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហា

«កោះតៃវ៉ាន់» ជាពាក្យមួយដែលអ្នកសិក្សាពិសេសជំនាញទំនាក់ទំនងអន្តរជាតិ ក៏ដូចជាអ្នកច្បាប់អន្តរជាតិមួយចំនួនតែងតែឮ និងតាមដានយ៉ាងយកចិត្តទុកដាក់ បន្ទាប់ពីបញ្ហាប្រឈមនៃវិបត្តិសង្គ្រាមរវាងរុស្ស៊ី-អ៊ុយក្រែន បញ្ហាប្រឈមនៃវិបត្តិសេដ្ឋកិច្ចសកល ជាពិសេសបញ្ហាក្ដៅគគុកនៃការដោះស្រាយមិនរួចនៃវិបត្តិក្នុងរយៈពេលកន្លងមក នៅមីយ៉ាន់ម៉ាដែលជាប្រទេសមួយស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ផងដែរ។ លើសពីនេះទៅទៀត ស្ថានភាពកោះតៃវ៉ាន់ មានភាពស្មុគស្មាញដែលអ្នកសិក្សាស្រាវជ្រាវ ក៏ដូចជាសិស្ស-និស្សិតមួយចំនួនពុំអាចកំណត់ជាក់ច្បាស់ពីបច្ចុប្បន្នភាពនៃកោះតៃវ៉ាន់មួយនេះ ដែលមានស្ថានភាព ក៏ដូចជាបរិបទអន្តរជាតិជាច្រើនទៀត ចាំបាច់ត្រូវសិក្សាស៊ីជម្រៅបន្ថែមទៀតស្របនឹងជម្លោះដែលតែងតែកើតមាននូវទិដ្ឋភាពមួយចំនួន។

ជាការពិតណាស់ រហូតមកទល់ពេលនេះបញ្ហាកោះតៃវ៉ាន់នៅតែមិនទាន់មានភាពដាច់ស្រេច ស្របពេលជាមួយគ្នា ក៏មានមន្ត្រីរបស់សហរដ្ឋអាមេរិក គឺលោកស្រីប្រធានសភា ណានស៊ី ប៉េឡូស៊ី បានធ្វើទស្សនកិច្ចមកកោះតៃវ៉ាន់ ហើយបានបង្កឱ្យមានភាពតានតឹង ពិសេសរវាងចិន និងកោះតៃវ៉ាន់ ដែលដំណើរទស្សនកិច្ចនេះធ្វើឡើងនៅដើមខែសីហា ឆ្នាំ២០២២។[1] ស្របពេលនោះផងដែរ ប្រទេសចិនក៏បានធ្វើសមយុទ្ធយោធាជុំវិញកោះតៃវ៉ាន់ ហើយភាគីខាងប្រទេសចិនក៏បានគម្រាមយ៉ាងខ្លាំងមុនពេលលោកស្រីដែលជាប្រធានសភានៃសហរដ្ឋអាមេរិកដែលមកទស្សនកិច្ចផងដែរ។[2] ក៏ប៉ុន្តែទោះបីចិនគម្រាមយ៉ាងណាក៏លោកស្រី នៅតែមកទស្សនកិច្ច។ រីឯភាគីចិនឯណោះវិញបានត្រឹមធ្វើសមយុទ្ធយោធា ដោយពុំមានការបាញ់ ឬប្រើយន្តហោះប្រដេញណាមួយតាម លោកស្រីប្រធានសភាអាមេរិកនោះឡើយ។ តែបើទោះបីជាមានស្ថានភាពយ៉ាងណាក៏ដោយ ក៏ត្រូវបានអ្នកសិក្សាគ្រប់មជ្ឈដ្ឋានទាំងអស់បានដាក់ជាសំនួរ និងជាចម្ងល់ មួយថា «តើកោះតៃវ៉ាន់ជាកោះឯករាជ្យ ឬជាផ្នែកមួយនៃដែនដីអធិបតេយ្យរបស់ប្រទេសចិន?»។

មុននឹងឈានចូលដល់ការសិក្សា វែកញែក ក៏ដូចជាការស្វែងយល់ឱ្យស៊ីជម្រៅតាមបែបផែននីមួយៗ ឬលើកយកនូវបច្ចុប្បន្នភាពក៏ដូចជាទឡ្ហីករណ៍ផ្សេងៗទៀត សូមលើកយកនូវប្រវត្តិសាស្ត្រនៃរដ្ឋាភិបាលកោះតៃវ៉ាន់ និងរដ្ឋាភិបាលនៃប្រទេសចិន។ នៅឆ្នាំ១៩៣៩ ដោយសារកត្តាសង្គ្រាមលោកលើកទី២ ផ្ទុះឡើងផង ដោយសារកត្តាសង្គ្រាមស៊ីវិលផង និងកត្តាជប៉ុនលុកលុយផង ទឹកដីនៃប្រទេសចិនត្រូវបានបែងចែកជា ៣ផ្នែក។ ផ្នែកខាងកើត

[1] សូមមើលគេហទំព័រ៖ https://www.reuters.com/world/asia-pacific/us-lawmakers-arrive-taiwan-thursday-report-2022-08-25/ ចុះផ្សាយនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២។ (ចូលមើលចុងក្រោយ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២២)

[2] សូមមើលគេហទំព័រ៖ https://www.reuters.com/world/pelosi-visit-taiwan-tuesday-taiwan-media-2022-08-01/ ចុះផ្សាយនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២។ (ចូលមើលចុងក្រោយ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២២)

ស្ថិតក្រោមការកាន់កាប់របស់ជប៉ុន ខាងលិច និងខាងត្បូង ស្ថិតក្រោមការកាន់កាប់របស់ លោក ចាង ខៃចៀក ចំណែកខាងផ្នែកពាយ័ព្យវិញ (ខាងលិចឆៀងខាងជើង) ស្ថិតក្រោមការកាន់កាប់របស់បក្សកុម្មុយនីស្ត ដឹកនាំដោយលោក ម៉ៅ សេទុង។ អំឡុងសង្គ្រាមលោកលើកទី២ ម៉ៅ សេទុង មានកងទ័ពជាង១លាននាក់ និងគ្រប់គ្រងដែនដី ដែលមានប្រជាជនជាង ១០០លាននាក់ ហើយចំណែកឯខាង ចាង ខៃចៀក ដែលទទួលបានជំនួយពីអាមេរិក មានចំនួនកងទ័ពច្រើនណាស់ តែគុណភាពអន់។[3] មេទ័ពរបស់ក្រុម ចាង ខៃចៀក ត្រូវបានតែងតាំង និងដំឡើងឋានៈ តាមរយៈបក្ខពួកនិយមដោយមិនខ្វល់ពីសមត្ថភាពឡើយ។ ដោយសារតែការមិនចេះគ្រប់គ្រងទ័ព បានធ្វើឱ្យទ័ពនៅតាមសមរភូមិខ្វះស្បៀង និងខ្វះគ្រឿងសព្វាវុធ។ ទីបំផុត ចាង ខៃចៀក ក៏ត្រូវបានចាញ់សង្គ្រាម។ នៅក្នុងឆ្នាំ១៩៤៩ កងទ័ពរបស់ ម៉ៅ សេទុង បានវាយចូលទីក្រុងណានជីង ដែលជាតំបន់រដ្ឋបាលរបស់ ចាង ខៃចៀក ធ្វើឱ្យរដ្ឋាភិបាលមួយនេះ រត់ទៅក្វាងទុង និងស៊ីឈាន់ ខណៈចុងក្រោយគេនោះ ត្រូវរត់ទៅកោះតៃវ៉ាន់។ ចាង ខៃចៀក បាននាំមន្ត្រី និងទ័ព ថែមទាំងសាច់ញាតិ ប្រហែលជិត២លាននាក់ និងបានប្រកាសយកក្រុងតៃប៉ិ នៅកោះតៃវ៉ាន់ ធ្វើជារដ្ឋធានីបណ្តោះអាសន្ននៃរបបសាធារណរដ្ឋចិនរបស់ខ្លួនតែម្តង។ ចំណែកឯចិនដីគោកទាំងមូល ត្រូវបានធ្លាក់ក្រោមការគ្រប់គ្រងបក្សកុម្មុយនីស្តចិន របស់លោក ម៉ៅ សេទុង ហើយលោកបានរៀបចំប្រទេសចិនសាជាថ្មី។ បន្ថែមលើនេះនៅថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៤៩ លោកប្រធាន ម៉ៅ សេទុង បានប្រកាសបង្កើតសាធារណរដ្ឋប្រជាមានិតចិន ដោយយកទីក្រុងប៉េកាំង ជារដ្ឋធានីចាប់ពីពេលនោះមក។

បញ្ហានៃការបែកបាក់នេះ ពិសេសកោះតៃវ៉ាន់ត្រូវបានកំណត់ នៅក្នុងរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតចិន ក្នុងផ្នែកមួយនៃ បុព្វកថា បានសរសេរយ៉ាងច្បាស់អំពីកោះតៃវ៉ាន់ដោយបានលើកឡើងថា «តៃវ៉ាន់គឺជាផ្នែកមួយនៃដែនដីពិសិដ្ឋនៃសាធារណរដ្ឋប្រជាមានិតចិន។ វាគឺជាកាតព្វកិច្ចដ៏ពិសិដ្ឋរបស់ប្រជាជនចិនទាំងអស់ រួមទាំងបងប្អូនជនជាតិចិនរបស់យើងនៅតៃវ៉ាន់ផងដែរ ដើម្បីសម្រេចបាននូវការបង្រួបបង្រួមជាតិមាតុភូមិដ៏អស្ចារ្យ។»[4] ហើយក៏បានចាត់ទុក សាធារណប្រជាមានិតចិន ជារដ្ឋាភិបាលស្របច្បាប់តែមួយគត់នៃប្រទេសចិន ក៏ជាវិធីសាស្ត្រមួយដែលបានធ្វើឱ្យពិភពលោកទទួលស្គាល់អំពី «គោលការណ៍ចិនតែមួយ One-China» និងជាគោលការណ៍របស់ប្រទេសចិនក្នុងការបង្រួបបង្រួម រវាងរដ្ឋាភិបាលតៃវ៉ាន់ ជាមួយ ចិនដីគោក។

[3] សូមមើលគេហទំព័រ៖ https://m.freshnewsasia.com/index.php/en/freshnewsplus/171651-2020-09-24-12-51-15.html ចុះផ្សាយនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២២។ (ចូលមើលចុងក្រោយ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២២)

[4] សូមមើលគេហទំព័រ៖ http://english.www.gov.cn/archive/lawsregulations/201911/20/content_WS5ed8856ec6d0b3f0e9499913.html ចូលមើលចុងក្រោយ នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២២។

## ២. ចំណោទបញ្ហា

បន្ទាប់ពីបានលើកឡើងនៅបញ្ហារដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតចិន ក៏ដូចជាគោលការណ៍ចិនតែមួយ និងទិដ្ឋភាពប្រវត្តិខ្លះៗដូចរៀបរាប់ខាងលើ បន្ទាប់ទៅនឹងលើកយកគោលការណ៍ភាពជារដ្ឋដែលនៅក្នុងក្របខណ្ឌ ឬជាលក្ខខណ្ឌទូទៅ មកសិក្សាបន្ថែម និងលើកយកទិដ្ឋភាពនៃស្ថាប័នអន្តរជាតិដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីតួនាទីជារដ្ឋ បញ្ហាប្រឈម ក៏ដូចជាស្ថានភាពនានា ដើម្បីជាទឡ្ហីករណ៍សិក្សាបន្ថែមឱ្យកាន់តែស៊ីជម្រៅពីបញ្ហាកោះតៃវ៉ាន់ ជាដំបូងយើងត្រូវសិក្សានូវទឡ្ហីករណ៍ទាំងទិដ្ឋភាពច្បាប់ នីតិអន្តរជាតិ ក៏ដូចជាទឡ្ហីករណ៍ខ្លះៗអំពីកោះតៃវ៉ាន់ (ផ្នែកទី១) មុននឹងសិក្សាអំពីស្ថានភាពឬទិដ្ឋភាពប្រឈមនៃការទទួលស្គាល់រដ្ឋដែលឆ្លុះបញ្ចាំងនៅក្នុងនីតិអន្តរជាតិ (ផ្នែកទី២) និងបន្តសិក្សាឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀតអំពីករណីកោះតៃវ៉ាន់ (ផ្នែកទី៣)។

## ៣. គោលបំណងនៃការស្រាវជ្រាវ

ដើម្បីឱ្យសារណា ឬការសិក្សាស្រាវជ្រាវនេះ មានភាពជោគជ័យនិងទទួលនូវលទ្ធផលល្អ យើងគួរគប្បីកំណត់គោលបំណងឱ្យបានច្បាស់លាស់ជាមុនសិន គោលបំណងទាំងនោះរួមមាន៖

- ស្វែងយល់អំពីគោលបំណង ព្រមទាំងចរិតលក្ខណៈនៃការទទួលស្គាល់រដ្ឋ
- ស្វែងយល់អំពីលក្ខខណ្ឌឬចំណុចសំខាន់ៗនៃការទទួលស្គាល់រដ្ឋ
- សិក្សាអំពីលក្ខខណ្ឌនៃការទទួលស្គាល់រដ្ឋ
- សិក្សាអំពីឧទាហរណ៍នៃប្រទេសផ្សេងៗជាគម្រូ
- សិក្សាអំពីស្ថានភាពប្រឈមនិងវិបត្តិនានា។

## ៤. ដែនកំណត់នៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវប្រធានបទស្តីពី «ការទទួលស្គាល់រដ្ឋ៖ ករណីកោះតៃវ៉ាន់» សារណានេះផ្តោតទៅលើការទទួលស្គាល់រដ្ឋមួយជារដ្ឋឯករាជ្យ។ ការទទួលស្គាល់នេះផ្អែកទៅលើទិដ្ឋភាពជាក់ស្តែងផ្សេងៗជាច្រើន ជាពិសេសបញ្ហាកោះតៃវ៉ាន់ ដែលនឹងត្រូវយកមកសិក្សាផ្នែកទ្រឹស្តីនិងការអនុវត្តជាក់ស្តែង រួមផ្សំនឹងការវែកញែកស្រាវជ្រាវ និងបកស្រាយនូវសេចក្តីលម្អិតទាំងអស់ដែលជាប់ពាក់ព័ន្ធក្នុងប្រធានបទខាងលើ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពីការទទួលស្គាល់រដ្ឋ ករណីកោះតៃវ៉ាន់ នឹងជួយពង្រឹងនូវការយល់ដឹងកាន់តែច្បាស់ ទាំងចំណេះដឹងខាងផ្នែកទ្រឹស្តី ការអនុវត្តជាក់ស្តែងពាក់ព័ន្ធនឹងការទទួលស្គាល់រដ្ឋ។ មួយចំណែកទៀត គឺផ្តល់ចំណេះដឹងពាក់ព័ន្ធនឹងស្ថានភាពក្នុងសង្គមផ្សាភ្ជាប់នឹងបញ្ហាប្រឈមក្នុងពិភពលោកនៃការប្រកាសខ្លួនជារដ្ឋ។

ការស្រាវជ្រាវពីការទទួលស្គាល់រដ្ឋក៏បានផ្តល់នូវការយល់ដឹងបន្ថែមក្នុងស្ថានភាពមួយចំនួនក្នុងការក្លាយជារដ្ឋឱ្យបានទូលាយជាមួយនឹងករណីសិក្សា នៃកោះតៃវ៉ាន់ដែលធ្លាប់តែមានបញ្ហាប្រឈមសឹងតែពុំអាចបែងចែកដាច់ស្រេច ពិសេសជាងនេះទៅទៀតការស្រាវជ្រាវនេះ នឹងផ្តល់ផលប្រយោជន៍ ចំណេះដឹង ដល់អ្នកសិក្សាជំនាន់ក្រោយ និងទុកជាឯកសារសម្រាប់ការស្រាវជ្រាវបន្ថែម។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

វិធីសាស្ត្រស្រាវជ្រាវនេះ គឺធ្វើឡើងតាមរបៀបស្វែងរក ពន្យល់ បកស្រាយ ប្រើឯកសារពាក់ព័ន្ធជាជំនួយក្នុងការបកស្រាយ និងបញ្ជាក់អត្ថន័យឱ្យបានកាន់តែច្បាស់។

### ១. ប្រមូលទិន្នន័យ

- មហាសន្និបាតអង្គការសហប្រជាជាតិ ឆ្នាំ១៩៧១
- អនុសញ្ញា ម៉ុងតេវីឌីអូ ស្តីពី សិទ្ធិ និង ករណីយកិច្ចរបស់រដ្ឋនានា ឆ្នាំ១៩៣៣
- គេហទំព័រ របស់ប្រទេសចិន និងកោះតៃវ៉ាន់
- គេហទំព័រនានា របស់សារព័ត៌មានពិភពលោក
- ឯកសារផ្សេងៗទៀតបានមកពីការស្វែងរកបានតាមប្រព័ន្ធអ៊ីនធើណេត បណ្ណាល័យ សៀវភៅមេរៀន និងឯកសារពាក់ព័ន្ធនានា។

### ២. ការបកស្រាយ និង វិភាគ

បន្ទាប់ពីឆ្លងកាត់ប្រមូលទិន្នន័យរួចហើយ ក្រុមយើងខ្ញុំបានធ្វើការជ្រើសរើសទិន្នន័យដែលពាក់ព័ន្ធខ្លឹមសារសំខាន់មកវែកញែកពិភាក្សាបកស្រាយ លើអត្ថន័យនៃការទទួលស្គាល់រដ្ឋ ជាពិសេសក្នុងករណីសិក្សា អំពីបញ្ហាកោះតៃវ៉ាន់។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

អត្ថបទសារណាក្រោមប្រធានបទ៖ «ការទទួលស្គាល់រដ្ឋ៖ ករណីកោះតៃវ៉ាន់» ត្រូវបានបែងចែកចេញជា បីជំពូក ដែលក្នុងនោះ រួមមាន សេចក្តីផ្តើម ជាផ្នែកដំបូងគេដែលរៀបរាប់អំពីលំនាំបញ្ហា ចំណោទបញ្ហា គោលបំណងនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ព្រមទាំងវិធីសាស្ត្រនៃការស្រាវជ្រាវ។ ចំពោះជំពូកទី១ សញ្ញាណទូទៅនៃរដ្ឋ ដែលនឹងធ្វើការសិក្សាអំពីនិយមន័យនៃរដ្ឋ និង ធាតុផ្សំនៃរដ្ឋ។ ចំណែកឯជំពូកទី២ ការទទួលស្គាល់រដ្ឋ នៅក្នុងនីតិអន្តរជាតិ ក្នុងជំពូកនេះផងដែរ យើងនឹងធ្វើការសិក្សាអំពី និយមន័យ និងមូលហេតុនៃការទទួលស្គាល់ ប្រភេទ និងទម្រង់នៃការទទួលស្គាល់ និង ផលវិបាកផ្នែកផ្លូវច្បាប់នៃការទទួលស្គាល់រដ្ឋ។ ហើយជំពូកចុងក្រោយ ដែលជាជំពូកទី៣ ករណីកោះតៃវ៉ាន់ នៅជំពូកចុងក្រោយនេះ យើងនឹងសិក្សាអំពីស្ថានភាពជាក់ស្តែងនៃកោះតៃវ៉ាន់ ការសិក្សាវិភាគ ពីចំណុចវិជ្ជមាន និងចំណុចអវិជ្ជមាន ហើយផ្នែកចុងក្រោយនៃសារណាបញ្ចប់ការសិក្សារបស់

យើងខ្ញុំនឹងបញ្ចប់ដោយមាន សេចក្តីសន្និដ្ឋាន និងអនុសាសន៍។ ផ្នែកចុងក្រោយនៃសារណា គឺជាការ សរុបសេចក្តីបញ្ចូល ខ្លឹមសារឡើងវិញនូវលទ្ធផលដែលបានធ្វើការស្រាវជ្រាវ និងផ្តល់នូវអនុសាសន៍មួយចំនួន សម្រាប់ជាដំណោះស្រាយបញ្ហាដែលបានកើតឡើងចំពោះការទទួលស្គាល់រដ្ឋ ជាពិសេសក្នុងករណីកោះតៃវ៉ាន់។

# ជំពូកទី១
# សញ្ញាណទូទៅនៃរដ្ឋ

# ជំពូកទី១

# សញ្ញាណទូទៅនៃរដ្ឋ

## ១.១ និយមន័យនៃរដ្ឋ

រដ្ឋ គឺជាអង្គភាពមួយដែលមានទឹកដីជាកំណត់ និងប្រជាពលរដ្ឋរស់នៅ ជាអចិន្ត្រៃយ៍ ហើយស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលខ្លួន ដែលមានសមត្ថកិច្ចធ្វើទំនាក់ទំនងជាធម្មតា ជាមួយរដ្ឋដទៃ។[5]

តាមច្បាប់អន្តរជាតិ រដ្ឋ គឺជាអង្គភាពមួយដែលមានទឹកដីកំណត់ និង ប្រជាពលរដ្ឋអចិន្ត្រៃយ៍ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលរបស់ខ្លួនហើយដែលមានសមត្ថកិច្ច ធ្វើទំនាក់ទំនងជាធម្មតាជាមួយរដ្ឋដទៃទៀត។[6]

រដ្ឋ គឺជាក្រុមមនុស្សដឹកនាំដោយអង្គការនយោបាយតែមួយដូចគ្នា និង ស្ថិតក្នុងលំហមួយជាកំណត់។[7] តាមន័យនយោបាយសង្គម ពាក្យថារដ្ឋ គឺសំដៅទៅសង្គមសរុបទាំងមូលដែលបែងចែកដាច់ស្រឡះ រវាងអ្នកដឹកនាំ និងអ្នកដែលត្រូវគេដឹកនាំហើយមានអំណាចនយោបាយមួយពិតប្រាកដ។

នៅក្នុងន័យវិទ្យាសាស្ត្ររដ្ឋបាលពាក្យថារដ្ឋ សំដៅទៅលើអំណាចដែលស្ថិតនៅលើអង្គការ គឺអង្គការនយោបាយអង្គការរដ្ឋបាល និងអង្គការតុលាការ។[8] នៅក្នុងន័យសង្គមស៊ីវិលរដ្ឋ គឺជាមនុស្ស មួយក្រុមដែល បានរស់នៅ ជាប់លាប់លើទឹកដីមួយក្រោមការគ្រប់គ្រងផ្ទាល់មុខ និងទៀងទាត់របស់រដ្ឋាភិបាលមួយ។

ជាការពិតណាស់ រដ្ឋជាប្រធាននៃច្បាប់អន្តរជាតិ[9] ហើយលើសពីនេះវាក៏ជាប្រធានពេញលេញមួយផងដែរ នេះមានន័យថារដ្ឋ មានសិទ្ធិ និងកាតព្វកិច្ច[10]។ តាមពិតទៅសិទ្ធ និងកាតព្វកិច្ចរបស់រដ្ឋ ពុំមែនមានតែក្នុងសៀវភៅនេះប៉ុណ្ណោះទេ សូម្បីអ្នកស្រាវជ្រាវ ពិសេសទៅទៀតនោះនៅក្នុងអនុសញ្ញាម៉ុងតេវីដេអូស្ដីពីសិទ្ធិ និងករណីកិច្ចរបស់រដ្ឋ ក៏បានលើកឡើងអំពីសិទ្ធ និងកាតព្វកិច្ចរបស់រដ្ឋ ផងដែរ។[11] មិនត្រឹមតែប៉ុណ្ណោះ រដ្ឋ អាចធ្វើ

---

[5] ដុំ អ៊ីម, ទំនាក់ទំនងអន្តរជាតិ, បោះពុម្ពលើកទី២(ភ្នំពេញ ៖ រោងពុម្ពជោគជ័យ, ២០១១), ១០៨

[6] ចាន់ ផារិទ្ធ, *ទំនាក់ទំនងអន្តរជាតិ*, (ភ្នំពេញ ២០១៥), ១២

[7] ចាន់ ផារិទ្ធ, *ទំនាក់ទំនងអន្តរជាតិ*, (ភ្នំពេញ ២០១៥), ១២

[8] ចាន់ ផារិទ្ធ, *ទំនាក់ទំនងអន្តរជាតិ*, (ភ្នំពេញ ២០១៥), ១២

[9] William, Perspectives on IL, *supra* note 1, p.35; Budislav Vukas and Trpimir M. Sosic, International Law: New Actors, New Concepts Continuing Dilemmas (Budislav, IL), 2010, p. 381, លោកបណ្ឌិត មាស បូរ៉ា, *នីតិអន្តរជាតិសាធារណៈ*, (ភ្នំពេញ ២០១៣), ទំព័រ ១៣។

[10] មាស បូរ៉ា, *នីតិអន្តរជាតិសាធារណៈ*, (ភ្នំពេញ ២០១៣), ទំព័រ១៣

[11] គេហទំព័រ៖ https://www.jus.uio.no/english/services/library/treaties/01/1-02/rights-duties-states.xml ចូលមើលចុងក្រោយនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២។

បណ្ដឹងទៅតុលាការអន្តរជាតិ និងមានឋានៈជានីតិបុគ្គលអន្តរជាតិ[12] (International Personality) តាមរយៈនេះ រដ្ឋក៏អាចចរចា ធ្វើការចុះសន្ធិសញ្ញានានាជាមួយប្រធានដទៃទៀតរបស់ច្បាប់អន្តរជាតិ ដូចជាអង្គការអន្តរជាតិ ផងដែរ។ តាមច្បាប់អន្តរជាតិ រដ្ឋគឺជាអង្គមួយដែលមានទឹកដីជាក់លាក់ ប្រជាពលរដ្ឋអចិន្ត្រៃយ៍ មានរដ្ឋាភិបាលគ្រប់គ្រង និងមានសមត្ថភាពចុះកិច្ចព្រមព្រៀងក្នុងទំនាក់ទំនងជាផ្លូវការជាមួយអង្គដទៃទៀតបាន។

នៅក្នុង អនុសញ្ញាម៉ុងតេវីដេអូ ស្ដីអំពីសិទ្ធិនិងករណីយកិច្ចរបស់រដ្ឋ ១៩៣៣ បានលើកឡើងនៅចំណុចដ៏សំខាន់បំផុតរបស់អនុសញ្ញានេះគឺ រដ្ឋក្នុងឋានៈជានីតិបុគ្គលនៃនីតិអន្តរជាតិ ត្រូវមានលក្ខណៈវិនិច្ឆ័យដូចតទៅ៖

ក. ប្រជាពលរដ្ឋអចិន្ត្រៃយ៍

ខ. ទឹកដីមួយជាកំណត់

គ. រដ្ឋាភិបាល

ឃ. សមត្ថភាពក្នុងការចូលទៅក្នុងទំនាក់ទំនងជាមួយរដ្ឋដទៃ

ប្រភេទផ្សេងៗនៃរដ្ឋមានដូចខាងក្រោម៖[13]

- **រដ្ឋឯករាជ្យ៖** គឺជារដ្ឋមិនស្ថិតនៅក្រោមការបង្គាប់បញ្ជា ឬ ការគ្រប់គ្រង របស់ រដ្ឋផ្សេងទៀត។
- **រដ្ឋចំណុះ៖** គឺជារដ្ឋដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋមួយផ្សេងទៀត ហើយឯករាជ្យរបស់រដ្ឋនេះមានកំណត់។
- **រដ្ឋអាណាព្យាបាល៖** គឺជារដ្ឋដែលស្ថិតក្រោមកិច្ចការពាររបស់រដ្ឋមួយទៀតដែលជាទូទៅច្រើន ជាប្រទេស មហាអំណាច។
- **រដ្ឋអព្យាក្រឹត្យ** គឺជារដ្ឋដែលមិនចងសម្ព័ន្ធមិត្តជាមួយប្លុកណាមួយ (ប្លុកសេរី ឬ ប្លុកសង្គមនិយម) រដ្ឋអព្យាក្រឹត្យ បើមានគេវាយប្រហារមកលើប្រទេសរបស់ខ្លួនប្រទេសផ្សេងៗ ឱ្យមកជួយខ្លួនបាន។
- រដ្ឋអព្យាក្រឹត្យគឺ៖
    - មិនចូលរួមធ្វើសង្គ្រាម
    - មិនចូលរួមជាមួយប្រទេសណាទាំងអស់ (រាប់អានស្មើៗគ្នា)
    - មិនចុះហត្ថលេខាចូលជាបក្សសម្ព័ន្ធណាមួយឡើយ
    - ត្រូវគោរពអព្យាក្រឹត្យភាពជានិច្ច។

គោលដៅនៃនយោបាយការបរទេសរបស់រដ្ឋគឺ

១- សន្តិសុខជាតិ (National security)

២- ស្វ័យភាពដឹកនាំជាតិ (National Autonomy)

៣- សុខុមាលភាពប្រជាពលរដ្ឋ (People's welfare)

[12] Budislav, IL, *supra* note 23, p. 99.

[13] ចាន់ ផារិទ្ធ, *ទំនាក់ទំនងអន្តរជាតិ*, (ភ្នំពេញ ២០១៥), ទំព័រទី ១

៤- តួនាទី ឋានៈ និង កិត្យានុភាពជាតិ (Status and Prestige)

ក្នុងលក្ខណវិនិច្ឆ័យឬការកំណត់អំពីរដ្ឋ ក៏ដូចជាធាតុផ្សំរបស់រដ្ឋក្តី នឹងសិក្សាបន្ថែមនូវចំណុចទាំង៣ខាងលើនេះ ក្នុងបរិបទនៃស្ថានភាពកោះតៃវ៉ាន់បច្ចុប្បន្ន និងលើកយកទឡ្ហីករណ៍ក្នុងករណីសិក្សានៃកោះតៃវ៉ាន់ជាពិសេសទឡ្ហីករណ៍ផ្សេងៗទៀតជាឧទាហរណ៍បន្ថែមដូចខាងក្រោម៖

## ១.២ ធាតុផ្សំនៃរដ្ឋ

### ១.២.១ ប្រជាពលរដ្ឋអចិន្ត្រៃយ៍

ប្រជាពលរដ្ឋ គឺជាធាតុចាំបាច់សម្រាប់រដ្ឋ ក្នុងបញ្ហាប្រជាពលរដ្ឋ កត្តាសំខាន់គឺបញ្ហាសញ្ជាតិ។[14] សញ្ជាតិមានន័យថា ជាទំនាក់ទំនងខាងផ្លូវច្បាប់ដែលកើតឡើងរវាងបុគ្គល និង ជាតិ។ សញ្ជាតិ គឺជាចំណងខាងផ្លូវច្បាប់ដែលបានរួមបញ្ចូលបុគ្គលម្នាក់ទៅនឹងរដ្ឋមួយ។

ដើម្បីទទួលបានសញ្ជាតិមួយគេត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖[15]

១-តាមរយៈកំណើត (By birth) មានន័យថាបុគ្គលម្នាក់អាចទទួលបាននូវសញ្ជាតិរដ្ឋមួយជាទីកន្លែងដែលខ្លួនបានកើត។

២- តាមរយៈសញ្ជាតូបនីយកម្ម (Naturalization) នៅក្នុងនីតិអន្តរជាតិសាធារណៈ សញ្ជាតូបនីយកម្ម គឺជាការចូលសញ្ជាតិតាមរយៈ ការសុំពីសាមីខ្លួន នូវសញ្ជាតិមួយថ្មីទៀតផ្សេងពីសញ្ជាតិដើម ប៉ុន្តែដើម្បីបានសញ្ជាតិថ្មី សាមីជនត្រូវបោះបង់សញ្ជាតិដើមរបស់ខ្លួន។

៣- តាមរយៈការតភ្ជាប់ (By resumption) នៅពេលខ្លះ បុគ្គលអាចបាត់បង់សញ្ជាតិរបស់ខ្លួន ដោយមូលហេតុមួយចំនួន ប៉ុន្តែក៏អាចបានសញ្ជាតិមកវិញតាមរយៈការតភ្ជាប់។

៤- តាមរយៈការដាក់ឱ្យនៅក្រោមអំណាច (By subjugation) កាលណារដ្ឋមួយចាញ់សង្គ្រាមរដ្ឋមួយទៀត ពលរដ្ឋនៃរដ្ឋចាញ់សង្គ្រាម ត្រូវស្ថិតនៅក្រោមអំណាច រដ្ឋឈ្នះសង្គ្រាមហើយអាចនឹងទទួលបានសញ្ជាតិ នៃរដ្ឋនោះ (មាននៅដើមសតវត្សរ៍ទី១៨, ១៩ )។

ការបាត់បង់សញ្ជាតិភាគច្រើនដំណើរការទៅតាមលក្ខខណ្ឌដូចខាងក្រោម៖[16]

[14] ចាន់ ដារិទ្ធ, *ទំនាក់ទំនងអន្តរជាតិ*, (ភ្នំពេញ ២០១៥), ទំព័រទី ២៣

[15] ចាន់ ដារិទ្ធ, *ទំនាក់ទំនងអន្តរជាតិ*, (ភ្នំពេញ ២០១៥), ទំព័រទី ២៣

[16] ចាន់ ដារិទ្ធ, *ទំនាក់ទំនងអន្តរជាតិ*, (ភ្នំពេញ ២០១៥), ទំព័រទី ២៣

ក- តាមរយៈការលាលែង (By release) ច្បាប់រដ្ឋខ្លះ ផ្ដល់ឱ្យពលរដ្ឋរបស់ខ្លួនបាត់បង់សញ្ជាតិតាមរយៈការលាលែង ឬ តាមរយៈពាក្យស្នើសុំ។

ខ- តាមរយៈការដកហូត (By deprivation) ច្បាប់រដ្ឋមួយចំនួន អាចដកហូតសញ្ជាតិពលរដ្ឋដើមរបស់ខ្លួន ឬ ពលរដ្ឋជាតិដទៃ ក្នុងករណីដែល មិនគោរពច្បាប់ទំលាប់រដ្ឋនោះ។

គ- ការស្នាក់នៅបរទេសយូរអង្វែង (Long residence abroad) ជាទូទៅការបាត់បង់សញ្ជាតិ គឺបណ្ដាលមកពីការស្នាក់នៅបរទេសយូរអង្វែង។

ឃ- តាមរយៈការបោះបង់សញ្ជាតិ (By renunciation) បុគ្គលអាចបោះបង់ចោលសញ្ជាតិរបស់ខ្លួន ដោយយោងទៅតាមតម្រូវការ កាលៈទេសៈបង្ខំ។ ប៉ុន្តែក្នុង លក្ខខណ្ឌនេះ បុគ្គលនោះត្រូវជ្រើសរើសសញ្ជាតិណាមួយដើម្បីជំនួសសញ្ជាតិដើមរបស់ខ្លួន។

តាមពិតទៅពាក្យថា «ប្រជាជន» និង «ប្រជាពលរដ្ឋ» តាមទស្សនវិទូបារាំងបានបញ្ជាក់ថា មានអត្ថន័យដូចគ្នា អាចប្រើមួយណាក៏បាន។ ប្រជាពលរដ្ឋ ត្រូវប្រមូលផ្ដុំដោយបុគ្គលទាំងឡាយ ដែលស្ថិតនៅក្រោមអំណាចរបស់រដ្ឋក្រោមម្លប់ឆត្រនៃច្បាប់រដ្ឋ។ ស្របគ្នានោះផងដែរ ក្នុងវចនានុក្រមសម្ដេចសង្ឃរាជជួនណាត ក៏បានសរសេរថា «ប្រជាពលរដ្ឋ ពលរដ្ឋគឺប្រជាជន ឬប្រជាជនដែលជាពលរដ្ឋ»។ ក៏ប៉ុន្តែបើយើងមើលទៅក្នុង *អនុសញ្ញាស្ដីពីសិទ្ធិ និងករណីយកិច្ចរបស់រដ្ឋ* បានចែងពីពាក្យ ប្រជាពលរដ្ឋ និងប្រជាជន ដែលក្នុងន័យច្បាប់ គឺមានចរិតខុសគ្នា។ ពាក្យថា «ប្រជាពលរដ្ឋ» សំដៅទៅលើជនទាំងឡាយណា ដែលរស់នៅក្រោមយុត្តាធិការរបស់រដ្ឋមួយ ហើយដែលមានសិទ្ធិបោះឆ្នោតមានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត និង មានសិទ្ធិនិងកាតព្វកិច្ចនៅចំពោះមុខច្បាប់។ អនុសញ្ញាស្ដីពីសិទ្ធិនិងករណីយកិច្ចរបស់រដ្ឋ ចែងថា រដ្ឋក្នុងឋានៈជានីតិអន្តរជាតិសាធារណៈ ត្រូវមានពលរដ្ឋអចិន្ត្រៃយ៍ មានន័យថា ប្រជាពលរដ្ឋនោះបានរស់នៅលើទឹកដីមួយដែលជាក់លាក់ ដែលទឹកដីគឺមានព្រំដែន និងការគ្រប់គ្រងតាមផ្លូវច្បាប់ពីសំណាក់រដ្ឋមួយ។ ប្រជាពលរដ្ឋ គឺជាសហគមន៍ ជាតិសាសន៍មួយ ដែលមិនត្រឹមតែស្ថិតនៅក្រោមច្បាប់របស់រដ្ឋ ប៉ុន្តែថែមទាំងត្រូវផ្សាភ្ជាប់នឹងកត្តាជាច្រើនទៀត ដូចជា កត្តាប្រវត្តិសាស្ត្រ កត្តាភាសា កត្តាទ្រឹស្ដីមនោគមវិជ្ជា ជាពិសេសលទ្ធិជាតិនិយម កត្តាវប្បធម៌ កត្តាសាសនា ជាដើម។ ជាការពិតណាស់ រដ្ឋពុំអាចមានអត្ថិភាពបាននោះឡើយ ប្រសិនបើគ្មានប្រជាពលរដ្ឋពិតប្រាកដ ឬជាប្រជាពលរដ្ឋដែលពុំបានផ្សាភ្ជាប់នឹងកត្តាទាំងអស់ខាងលើនេះ។ តាមពិតទៅនៅក្នុងរដ្ឋមួយ គេពុំអាចកំណត់បាននូវចំនួនប្រជាពលរដ្ឋយ៉ាងច្បាស់ថាកម្រិតមនុស្សប៉ុន្មាននាក់ ទើបអាចកំណត់បានថាជារដ្ឋមួយនោះ ពុំទាន់អាចកំណត់បានឡើយ ហើយក៏ពុំមានខ្នាតអ្វីជាក់លាក់មកកំណត់ ឬវាស់ចំនួនប្រជាពលរដ្ឋ ឬប្រជាពលរដ្ឋធៀបនឹងផ្ទៃដីនៃដែនដីរដ្ឋមួយបានដែរ។

ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏គេត្រូវកំណត់ឱ្យបាននូវកត្តាជាច្រើន រួមផ្សំនឹងសញ្ជាតិដើមរបស់ប្រជាពលរដ្ឋមួយដែលរស់នៅក្នុងរដ្ឋនោះយ៉ាងច្បាស់។ បើមានតែប្រជាជន ឬប្រជាពលរដ្ឋ តែប្រជាពលរដ្ឋនោះមានសញ្ជាតិផ្សេងខុសពីជាតិសាសន៍ ដែលខ្លួនបានរស់នៅនោះគេពុំចាត់ទុកថាគាត់ជាប្រជាពលរដ្ឋនៃរដ្ឋមួយនោះឡើយ ហើយរដ្ឋនោះក៏ពុំអាចជារដ្ឋមានលក្ខណៈពេញលេញនោះឡើយ ដោយហេតុថាមានត្រឹមតែទឹកដីហើយពុំមានមនុស្ស ឬហៅថាជាប្រជាពលរដ្ឋរស់នៅសោះនោះឡើយ។ អាចបកស្រាយបានមួយបែបទៀតថា ប្រសិនបើចំនួននៃប្រជាពលរដ្ឋរបស់ប្រទេសមួយមានចំនួនតិចតួចខ្លាំងពេក អាចធ្វើឱ្យការដំណើរការប្រទេសនោះនឹងជួបប្រទះការលំបាក ពីព្រោះប្រឈមនឹងបញ្ហាកង្វះកម្លាំង ឬអាចជាកង្វះធនធានមនុស្សគ្រប់គ្រងដើម្បីឱ្យមាននូវដំណើរការសេវារបស់រដ្ឋមួយ។

តាមន័យទូលាយ ប្រជាពលរដ្ឋ ត្រូវរួមផ្សំឡើងដោយជនជាតិរបស់រដ្ឋខ្លួនផង និងជនបរទេសដែលកំពុងស្ថិតនៅលើទឹកដីរបស់ខ្លួនផង។ ជនជាតិរបស់រដ្ឋមានន័យថា ជាជនទាំងឡាយ (រូបវន្តបុគ្គល និងនីតិបុគ្គល) ដែលមានសញ្ជាតិរបស់រដ្ឋនោះ។ ជនទាំងនោះគិតទាំងអ្នកដែលទៅរស់នៅឯបរទេស តែពួកគាត់នៅរក្សាទុកសញ្ជាតិប្រទេសដើមរបស់ពួកគាត់។ ចំណែកឯជនបរទេស គឺជាជនទាំងឡាយណា ដែលរស់នៅលើទឹកដីប្រទេសណាមួយ ដែលខ្លួនគ្មានសញ្ជាតិ ហើយគាត់មានចំណងសញ្ជាតិជាមួយនឹងរដ្ឋដទៃណាមួយទៅវិញ។

ប្រជាពលរដ្ឋនៃប្រទេសមួយ តាមន័យចង្អៀតសំដៅលើបុគ្គលទាំងឡាយណា ដែលមានចំណងគតិយុត្តជាមួយនឹងរដ្ឋនោះ (គឺសំដៅលើសញ្ជាតិតែម្តង)។ គឺប្រជាពលរដ្ឋក្នុងន័យនេះហើយ ដែលគេចាត់ជាធាតុផ្សំនៃរដ្ឋ។

ជាការពិតណាស់ ក្នុងស្ថានភាពជាក់ស្តែងរបស់កោះតៃវ៉ាន់គឺពិតជាមានសញ្ជាតិតៃវ៉ាន់ ក៏ដូចជាការប្រើប្រាស់ជាលិខិតឆ្លងដែនរបស់តៃវ៉ាន់ ហើយក៏មាននូវច្បាប់មួយចំនួនទាក់ទងនឹងសញ្ជាតិ ក៏ដូចជាលិខិតឆ្លងដែនតៃវ៉ាន់ដែលមានកំណត់ក្នុងច្បាប់សញ្ជាតិ (Nationality Act) នៃកោះតៃវ៉ាន់ ក្នុងឆ្នាំ២០២១។[17]

### ១.២.២ ទឹកដីមួយជាក់លាក់

ទឹកដី រួមផ្សំដោយលំហសំខាន់ៗបី គឺ៖ [18]

- លំហដែនគោក (Territorial space)
- លំហដែនទឹក (Maritime space)
- លំហដែនអាកាស (Air space)

ប្រសិនបើគ្មានទឹកដីទេ គេមិនអាចហៅថា រដ្ឋបានឡើយ ពីព្រោះទឹកដីគឺជាលំហមួយ ដើម្បីឱ្យរដ្ឋ ដំណើរការសកម្មភាព និងអនុវត្តនូវអំណាចរបស់ខ្លួន ទោះបីទឹកដីតូច ឬ ធំ ក៏ដោយ។

[17] គេហទំព័រ៖ https://law.moj.gov.tw/ENG/LawClass/LawAll.aspx?pcode=D0030001 ចូលមើលចុងក្រោយនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២។

[18] ចាន់ ផារិទ្ធ, *ទំនាក់ទំនងអន្តរជាតិ*, (ភ្នំពេញ ២០១៥), ទំព័រទី ១៨

លំហដែនគោក គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋមួយ ហើយផ្សារភ្ជាប់ទៅនឹង បញ្ហាសំខាន់ៗជាយុទ្ធសាស្ត្រដូចជា៖

- ជាឧបករណ៍ចំណងភ្ជាប់ទៅនឹងប្រជាពលរដ្ឋ
- បញ្ហាសន្តិសុខជាតិ
- ការការពារអន្តរាគមន៍ពីខាងក្រៅ
- បញ្ហាអត្តសញ្ញាណជាតិ ការកំណត់ព្រំដែនគោក

ដែនដី គឺជាលំហមួយសម្រាប់ឱ្យរដ្ឋធ្វើសកម្មភាពនៃអំណាចរបស់រដ្ឋនៅក្នុងអធិបតេយ្យពេញលេញស្របតាមនីតិអន្តរជាតិ។[19] ដូច្នេះដើម្បីកំណត់អំពីអធិបតេយ្យរបស់រដ្ឋ ចាំបាច់ណាស់ត្រូវមានព្រំដែន ឬព្រំប្រទល់។

តាមពិតទៅទឹកដីមួយជាកំណត់ ឬដែនដីមួយជាកំណត់ គេពុំអាចកំណត់វាបានថាមានទំហំតូច ឬធំឱ្យប្រាកដទេ ក្នុងន័យនេះចង់សម្តៅថា ទឹកដីមួយទោះតូច ឬធំក្តី ត្រូវកំណត់ដោយព្រំប្រទល់ ឬព្រំដែន ទោះបីជាព្រំដែន ឬព្រំប្រទល់ ទោះវាជាព្រំប្រទល់ដែនដីគោកក្តី ឬដែនដីទឹកក៏ដោយ។ ដើម្បីយល់អត្ថន័យនៃឃ្លាខាងលើនេះកាន់តែច្បាស់ សូមលើកយកករណី បុរីវ៉ាទីកង់ (Vatican City) ជាប្រទេសមួយដែលមានទំហំផ្ទៃដីត្រឹមតែ 0.49 គីឡូម៉ែត្រការ៉េ (0.19 ម៉ាយការ៉េ)[20] និងជាប្រទេសមួយដែលតូចបំផុតនៅក្នុងពិភពលោក (សង្គមអន្តរជាតិបានទទួលស្គាល់បុរីវ៉ាទីកង់ក្នុងឋានៈដូចជារដ្ឋ)។

លើសពីនេះដើម្បីបង្កើតបានជារដ្ឋមួយ ក្នុងច្បាប់អន្តរជាតិ ពុំបានទាមទារនូវគ្រប់ចំណុចជាក់លាក់ ១០០ភាគរយ នៃព្រំដែននោះឡើយ។ ទោះបីជាយ៉ាងណាច្បាប់អន្តរជាតិក៏មានការកំណត់ជាក់លាក់អំពីខ្នាត ឬរបៀបនៃការកំណត់ច្បាស់លាស់អំពី ដែនដី ទោះបីជា ក្រោមសមុទ្រ លើដី ឬលើអាកាសក៏ដោយ។

ដែនដី រាប់បញ្ចូលនូវដីរបស់ស្ថានទូតបរទេស ដែលតាំងនៅក្នុងរដ្ឋនោះ។ ដីរបស់ស្ថានទូត ត្រូវបានប្រគល់ដោយរដ្ឋ ផ្អែកទៅតាមគោលការណ៍ទៅវិញទៅមកសម្រាប់ប្រតិបត្តិការទូត ក្នុងរយៈពេលយូរអង្វែងណាមួយ តែវានៅតែជាដីរបស់រដ្ឋដែលប្រគល់នោះ។ គេពុំគួរមានការយល់ច្រឡំថា ដីនោះជាដីរបស់រដ្ឋដាក់ទូតទេ។ រដ្ឋដែលទូតតាំងនៅ មិនហ៊ានចូលក្នុងទូត ដោយគ្មានការអនុញ្ញាត ដោយសារខ្លួនមានកាតព្វកិច្ចតាមច្បាប់អន្តរជាតិ ឱ្យគោរពនូវអភ័យឯកសិទ្ធិទូត។

---

[19] ពៅ សាវឿន, *ទំនាក់ទំនងអន្តរជាតិ*, (ភ្នំពេញ ២០០៩), ទំព័រទី ៩

[20] គេហទំព័រ៖ https://vatican-city-tickets.com/km/facts-about-the-vatican-city/ ចូលមើលចុងក្រោយ នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០២៣។

ជាការពិតណាស់ តៃវ៉ាន់ មាននូវដែនដីអចិន្ត្រៃយ៍ ដែលនៅម្ខាងនៃការទទួលស្គាល់រដ្ឋ គឺមានបញ្ហាទឹកដីជាបញ្ហាស្នូលមួយទៀត។ គោលការណ៍នៃអធិបតេយ្យភាពដែនដី ឬបូរណភាពទឹកដី របស់ចិនក្នុងនាមជារដ្ឋ។ ក្នុងបញ្ហានេះសូមធ្វើការលើកយកនូវបទពិសោធន៍ខ្លះៗនៃទិដ្ឋភាព នៃឯករាជ្យកូសូវ៉ូ៖[21]

បន្ទាប់ពីការដួលរលំនៃ សហភាពសូវៀត និងការត្រួតត្រារបស់ខ្លួនលើអឺរ៉ុបខាងកើតនៅក្នុងឆ្នាំ1991 សមាសភាគ នៃមណ្ឌល យូហ្គោស្លាវី បានចាប់ផ្តើមរំលាយ។ សម្រាប់ពេលខ្លះស៊ែប៊ីរក្សាឈ្មោះនៃសាធារណរដ្ឋសហព័ន្ធយូហ្គោស្លាវី ហើយស្ថិតក្រោមការគ្រប់គ្រងប្រល័យពូជសាសន៍ Slobodan Milosevic ដែលបានកាន់កាប់ដោយកាន់កាប់នូវខេត្តនៅក្បែរនោះ។ ក្រោយមកដែនដីដូចជា Bosnia និង Herzegovina និង Montenegro ទទួលបានឯករាជ្យភាព។ តំបន់សេសសល់ខាងត្បូងនៃកូសូវ៉ូនៅតែជាផ្នែកមួយនៃប្រទេសស៊ែប៊ី។ កងកម្លាំងរំដោះកូសូវ៉ូបានប្រយុទ្ធជាមួយកងកម្លាំងស៊ែប៊ីរបស់ Milosevic ហើយសង្គ្រាមឯករាជ្យមួយបានកើតឡើងចាប់ពីឆ្នាំ ១៩៩៨ ដល់ ១៩៩៩។

នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បានអនុម័តដំណោះស្រាយមួយដែលបានបញ្ចប់សង្គ្រាមបានបង្កើត កងកម្លាំង ថែរក្សាសន្តិភាព ណាតូ មួយនៅកូសូវ៉ូ ហើយបានផ្តល់សិទ្ធិស្វ័យភាពមួយចំនួនដែលរួមមានសមាជិកសភា ១២០នាក់។ ក្នុងរយៈពេលយូរបំណងប្រាថ្នារបស់កូសូវ៉ូដើម្បីឯករាជ្យពេញលេញបានកើនឡើង។ សហប្រជាជាតិ សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក បានធ្វើការជាមួយកូសូវ៉ូដើម្បីបង្កើតផែនការឯករាជ្យមួយ។ រុស្ស៊ីគឺជាបញ្ហាប្រឈមដ៏ធំមួយចំពោះឯករាជ្យរបស់កូសូវ៉ូពីព្រោះរុស្ស៊ីដែលជាសមាជិកក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិដែលមានអំណាចវ៉េតូ (វ៉េតូ) បានសន្យាថាពួកគេនឹងបដិសេធនិងរៀបចំផែនការដើម្បីឯករាជ្យរបស់កូសូវ៉ូដែលមិនបានដោះស្រាយកង្វល់របស់ស៊ែប៊ី។

ដែនអាកាសនៃរដ្ឋមួយ គឺសំដៅទៅលើលំហអាកាសនៅពីលើដែនគោកនិងសមុទ្រដែនដី។[22] រដ្ឋម្ចាស់ដែនអាកាសមានសិទ្ធិ ពេញលេញលើដែនអាកាសរបស់ខ្លួន។

កាលណានិយាយអំពីលំហអាកាសគេត្រូវស្គាល់អនុសញ្ញាអន្តរជាតិបីគឺ៖

- អនុសញ្ញាទីក្រុងប៉ារីស ១៩១៩

---

[21] ដកស្រង់ចេញពីវេបសាយ៖ https://km.eferrit.com/%E1%9E%AF%E1%9E%80%E1%9E%9A%E1%9E%B6%E1%9E%87%E1%9F%92%E1%9E%99%E1%9E%9A%E1%9E%94%E1%9E%9F%E1%9F%8B%E1%9E%80%E1%9E%BC%E1%9E%9F%E1%9E%BC%E1%9E%9C%E1%9F%89%E1%9E%BC/ សរសេរដោយ Matt Rosenberg។ (ចូលមើលចុងក្រោយ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២)

[22] ពៅ សារឿន, *ទំនាក់ទំនងអន្តរជាតិ*, (ភ្នំពេញ ២០០៩), ទំព័រទី ១១

- អនុសញ្ញា Warsaw (Vasovie) ១៩២៩
- អនុសញ្ញា Chicago ១៩៤៤។

អនុសញ្ញាទាំងបីនេះបាននិយាយស្ដីពីការគ្រប់គ្រងដែនអាកាសហើយដែលដែនអាកាសចែកជាពីរគឺ ដែនអាកាសរបស់រដ្ឋ និងដែលអាកាសអន្តរជាតិ។ ដែនអាកាសអន្តរជាតិគ្រប់គ្រងដោយអង្គការស៊ីវិលអន្តរជាតិ International Civil Aviation Organization (ICAO)។ អង្គការ នេះបង្កើតឡើងនៅឆ្នាំ ១៩៤៧ តាមរយៈអនុសញ្ញា Chicago មានទីស្នាក់ការនៅទីក្រុង ម៉ុងរេអាល់ ប្រទេសកាណាដា។ លំហដែនអាកាស (Air space) គឺរដ្ឋទាំងអស់មានសេរីភាពលើដែនអាកាសទាំងអស់គ្នា ប៉ុន្តែបើស្ថិតនៅលើកម្ពស់មួយកំណត់ វាក្លាយជាលំហអាកាសអន្តរជាតិ។[23] ជាទូទៅរដ្ឋនីមួយៗ មានសិទ្ធិរក្សាអធិបតេយ្យភាពទឹកដីរបស់ខ្លួនទាំងដែនទឹក ដែនអាកាស និងដែនគោក។

អនុសញ្ញាទីក្រុងបារីស ស្ដីពីការហោះហើរផ្លូវអាកាសឆ្នាំ ១៩១៩ (Aerial Navigation) ក្នុងនោះមានសំខាន់ៗដូចតទៅ៖

ក- ស្របតាមអនុសញ្ញានេះ រដ្ឋនីមួយៗមានសិទ្ធិពេញលេញនៅលើដែនអាកាសរបស់ខ្លួន។

ខ- ក្នុងពេលមានសន្តិភាព យន្តហោះរបស់រដ្ឋមួយមិនអាចហោះឆ្លងកាត់រដ្ឋមួយទៀតបានទេ ក្នុងករណីដែលគ្មានកិច្ចព្រមព្រៀងជាមួយគ្នា។

គ- ការហោះហើរឆ្លងកាត់របស់រដ្ឋនីមួយៗ ត្រូវធានាឱ្យបាននូវសុវត្ថិភាព។

សិទ្ធិក្នុងលំហដែនអាកាស៖[24]

- រដ្ឋមានយុត្តាធិការផ្ដាច់មុខលើលំហដែនអាកាសរបស់ខ្លួន។
- យន្តហោះមិនមានសិទ្ធិហោះឆ្លងកាត់។ ការប្រើប្រាស់ដែនអាកាសទាមទារឱ្យមានការយល់ព្រម។
- យន្តហោះស្ថិតក្នុងលំហអាកាសអន្តរជាតិ ត្រូវស្ថិតនៅក្រោមយុត្តាធិការជាតិរបស់ខ្លួន (ការពិនិត្យមើលទង់ជាតិ)។
- រដ្ឋមិនអាចប្រើប្រាស់ឧបករណ៍មើលពីលើមេឃយានអវកាសអាចប្រើប្រាស់បាន។

ពាក់ព័ន្ធកិច្ចការសមុទ្រ គឺសហគមន៍អន្តរជាតិបានបើកសន្និសីទមួយសម្រាប់ការរៀបចំច្បាប់សមុទ្រគឺសន្និសីទសហប្រជាជាតិស្ដីពីនីតិសមុទ្រដែលភាសាអង់គ្លេសហៅថា UNCLOS (United Nations Conference on the Law of the Sea) នៅទីក្រុងសឺណែវ នាឆ្នាំ១៩៥៨។[25] UNCLOS II ដំណើរការ ក្នុងឆ្នាំ ១៩៦០

[23] ចាន់ ដារិទ្ធ, *ទំនាក់ទំនងអន្តរជាតិ*, (ភ្នំពេញ ២០១៥), ទំព័រទី ២១

[24] ចាន់ ដារិទ្ធ, *ទំនាក់ទំនងអន្តរជាតិ*, (ភ្នំពេញ ២០១៥), ទំព័រទី ២២

[25] ចាន់ ដារិទ្ធ, *ទំនាក់ទំនងអន្តរជាតិ*, (ភ្នំពេញ ២០១៥), ទំព័រទី ១៩

UNCLOS III ដំណើរការ ក្នុងឆ្នាំ១៩៧៣ UNCLOS IV ដំណើរការក្នុងឆ្នាំ ១៩៨២ នៅទីក្រុង Montego Bay ប្រទេស Jamaica។

នៅក្នុងអនុសញ្ញាអង្គការសហប្រជាជតិស្តីពីនីតិសមុទ្រទីមួយ គេបានចុះហត្ថលេខា និង អនុម័តទៅលើអនុសញ្ញាចំនួនបួនទៀតគឺ :

ក- អនុសញ្ញាស្តីពីដែនសមុទ្រ និង តំបន់តភ្ជាប់ (Convention on the Territorial Sea and Contiguous zone)

ខ- អនុសញ្ញាស្តីពីតំបន់នាយសមុទ្រ/សមុទ្រអន្តរជាតិ (Convention on the High Sea)

គ- អនុសញ្ញាស្តីពីការនេសាទ និង ការរក្សាទុកនូវធនធានធម្មជាតិមានជីវិត (Convention on Fishing and Conservation of Living Resources)

ឃ- អនុសញ្ញាស្តីពីតំបន់ខ្ពង់រាបបាតសមុទ្រ (Convention on the Continental Shelf)

អនុម័តអនុសញ្ញាទីក្រុង Montego Bay ប្រទេស Jamaica ដែលមានប្រទេសចំនួន១២០ បានចូលរួមបានកំណត់ដែនសមុទ្ររដ្ឋនីមួយៗ ដូចតទៅ៖[26]

- តំបន់ដែនទឹកក្នុង (internal waters)តំបន់នេះ រាប់បញ្ចូលនូវឆ្នេរសមុទ្ររបស់រដ្ឋ កំពង់ផែដែសមុទ្រ ដែលជាអធិបតេយ្យភាពរបស់រដ្ឋនីមួយៗ។ នាវាបរទេសរាប់ទាំងនាវាដឹកអ្នកដំណើរបរទេសមិនអាចចូលក្នុងតំបន់នេះបានទេប្រសិនបើពុំមានការអនុញ្ញាត្តិពីអាជ្ញធរនៃរដ្ឋនេះ។
- តំបន់សមុទ្រដែនដី (Territorial Sea) មានចម្ងាយ១២ ម៉ាយល៍ ពីខ្សែបន្ទាត់មូលដ្ឋាន។
- តំបន់តភ្ជាប់ (Contiguous zone) មានចម្ងាយ ២៤ម៉ាយល៍ ពីខ្សែមូលដ្ឋាន។
- តំបន់ខ្ពង់រាបបាតសមុទ្រ (Continental shelf) មានចម្ងាយ ២០០ ម៉ាយល៍ ពីខ្សែបន្ទាត់មូលដ្ឋាន។
- តំបន់សេដ្ឋកិច្ចផ្តាច់មុខ (Economic exclusive zone) មានចម្ងាយ ២០០ ម៉ាយល៍ ពីខ្សែមូលដ្ឋាន។ រដ្ឋនីមួយៗ មានសិទ្ធិពេញលេញ និង ផ្តាច់មុខលើធនធាន និង រ៉ែលើដែនទឹកនោះ ទាំងផ្នែកខាងលើ និង ផ្នែកខាងក្រោម។
- តំបន់សមុទ្រអន្តរជាតិ (High Sea /International Sea) ជាតំបន់ផ្ទៃសមុទ្រអន្តរជាតិ មិនមែនជាកម្មសិទ្ធិរបស់រដ្ឋណាមួយឡើយ ពិភពលោកទាំងមូលអាចធ្វើ ចរាចរការហោះហើរដោយរាប់ទាំងការស្រាវជ្រាវវិទ្យាសាស្រ្ត និង នេសាទទៀតផង។ នៅក្នុងដែនទឹកអន្តរជាតិនេះ រដ្ឋទាំងអស់មានសិទ្ធិក្នុងការប្រើប្រាស់ស្មើៗគ្នា ដូចជាការនេសាទ ការដឹកជញ្ជូន ឬ គោលបំណងផ្សេងៗទៀត។

[26] ចាន់ ផារិទ្ធ, *ទំនាក់ទំនងអន្តរជាតិ*, (ភ្នំពេញ ២០១៥), ទំព័រទី ២០

**១.២.៣ រដ្ឋាភិបាល**

រដ្ឋាភិបាល គឺជាធាតុដ៏សំខាន់ទីបីរបស់រដ្ឋ[27]។ រដ្ឋាភិបាល គឺជាធាតុដ៏សំខាន់ទីបីរបស់រដ្ឋ។ រដ្ឋាភិបាល នៅក្នុងឆាកអន្តរជាតិបច្ចុប្បន្នមានលក្ខណៈស្របច្បាប់ និង មានសមត្ថកិច្ចក្នុងទំនាក់ទំនងអន្តរជាតិរដ្ឋាភិបាល ដទៃទៀតដូខាងក្រោម៖

១- ជារដ្ឋាភិបាលកើតចេញពីការទុកចិត្តរបស់ប្រជាពលរដ្ឋ

២- ជារដ្ឋាភិបាលដែលមានការគាំទ្រដ៏ច្រើនលើសលប់ ពីសំណាក់ប្រជាពលរដ្ឋ

៣- រដ្ឋាភិបាលនោះគ្រប់គ្រងទឹកដីមួយភាគធំ ឬ ទាំងស្រុងពេញផ្ទៃប្រទេស

៤- មានសមត្ថកិច្ចធ្វើទំនាក់ទំនងជាមួយ នឹង រដ្ឋដទៃទៀត។

ក្នុងនាមជានីតិបុគ្គល រដ្ឋអាចតំណាងឡើងដោយ អង្គការនយោបាយទាំងឡាយ ដែលប្រមូលផ្តុំដោយបុគ្គលជាច្រើន ហើយអាចចូលរួមក្នុងទំនាក់ទំនងជាមួយរដ្ឋដទៃទៀតបាន។ រដ្ឋាភិបាល គឺជាធាតុផ្សំមួយក្នុងចំណោមធាតុផ្សំទាំង៣ ដែលអាចបង្កើតជារដ្ឋបាន។ រដ្ឋាភិបាលនៅទីនេះមិនមែនសំដៅលើតែ ជាអង្គការនីតិប្រតិបត្តិតែមួយប៉ុណ្ណោះរបស់រដ្ឋណាមួយទេ តែវាត្រូវប្រមូលផ្តុំនូវរចនាសម្ព័ន្ធរដ្ឋទាំងអស់តែម្តង ដូចជាអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ អំណាចតុលាការ និងរដ្ឋបាលសាធារណៈរបស់រដ្ឋទាំងមូលតែម្តង។ រដ្ឋាភិបាលសំដៅលើអ្នកដែលតំណាងឱ្យរដ្ឋខ្លួនឯងនេះតែម្តង។

ឋានៈជារដ្ឋត្រូវមានការឆ្លុះបញ្ចាំងតាមរយៈការបង្កើតរដ្ឋាភិបាល ពិតប្រាកដមួយ ដែលកត្តាទាំងអស់នេះ បើយើងក្រឡេកមើលទិដ្ឋភាពកោះតៃវ៉ាន់ឯណោះវិញមានការបង្កើតរដ្ឋាភិបាល ពិសេសតាមរយៈការបោះឆ្នោតជ្រើសរើសអ្នកតំណាងរបស់ខ្លួន។ ហើយក៏ពុំមែនមានត្រឹមតែអ្នកតំណាងប៉ុណ្ណោះនោះទេ ថែមទាំងមាននូវស្ថាប័នដឹកនាំនានាថែមទៀតផង។

សូមគូសបញ្ជាក់ផងដែរថា ប្រព័ន្ធនយោបាយរបស់តៃវ៉ាន់ មានប្រធានាធិបតី និងអនុប្រធានាធិបតី ដែលត្រូវជ្រើសរើសតាមរយៈការបោះឆ្នោតក្នុងរយៈពេល៤ឆ្នាំម្តង។ ក្នុងការបោះឆ្នោតនីតិប្បញ្ញត្តិរបស់តៃវ៉ាន់ អ្នកបោះឆ្នោតម្នាក់ៗ បោះឆ្នោតសម្រាប់ថ្នាក់ស្រុកផង និងការបោះឆ្នោតសម្រាប់ថ្នាក់ជាតិផង។ ប្រធានាធិបតីគឺជាប្រមុខរដ្ឋ និងជាមេបញ្ជាការនៃកងកម្លាំងប្រដាប់អាវុធ តំណាងឱ្យប្រទេសជាតិក្នុងទំនាក់ទំនងបរទេស ហើយត្រូវបានផ្តល់សិទ្ធិអំណាចក្នុងការតែងតាំងប្រធានផ្នែកទាំងបួនរបស់រដ្ឋាភិបាល រួមទាំងនាយករដ្ឋមន្ត្រី ដែលជាអ្នកដឹកនាំប្រតិបត្តិ Yuan ឬគណៈរដ្ឋមន្ត្រី ហើយត្រូវរាយការណ៍ ជាប្រចាំចំពោះនីតិប្បញ្ញត្តិ Yuan ឬនីតិប្បញ្ញត្តិ។ ប្រធានក្រសួងគណៈកម្មាការ និងទីភ្នាក់ងារក្រោមការគ្រប់គ្រងរបស់ Yuan ត្រូវបានតែងតាំងដោយនាយករដ្ឋមន្ត្រី និង

[27] ចាន់ ផារិទ្ធ, *ទំនាក់ទំនងអន្តរជាតិ*, (ភ្នំពេញ ២០១៥), ទំព័រទី ២៦

បង្កើតក្រុមប្រឹក្សាប្រតិបត្តិ Yuan។ ដើម្បីបង្កើនប្រសិទ្ធភាពរដ្ឋបាល នាយកប្រតិបត្តិ Yuan កំពុងដំណើរការរៀបចំរចនាសម្ព័ន្ធឡើងវិញ ដើម្បីកាត់បន្ថយចំនួនអង្គភាពថ្នាក់គណៈរដ្ឋមន្ត្រីពី ៣៧ ទៅ ២៩។

បន្ទាប់ពីការរៀបចំឡើងវិញដែលបានចាប់ផ្តើមនៅដើមឆ្នាំ២០១២ នាយកប្រតិបត្តិ Yuan នឹងមានក្រសួងចំនួន ១៤ ក្រុមប្រឹក្សាចំនួនប្រាំបួន ទីភ្នាក់ងារឯករាជ្យចំនួនបី និងអង្គការចំនួនបួនផ្សេងទៀត។ នៅក្រោមរដ្ឋធម្មនុញ្ញ ROC ទាំងការតែងតាំងនាយករដ្ឋមន្ត្រី ឬនាយករដ្ឋមន្ត្រីតែងតាំងជារដ្ឋមន្ត្រី មិនមែនជាកម្មវត្ថុនៃការបញ្ជាក់ផ្នែកនីតិប្បញ្ញត្តិទេ។

ការតែងតាំងប្រធានាធិបតីនៃសមាជិកនៃការត្រួតពិនិត្យ Yuan និងការប្រឡង Yuan ក៏ដូចជាយុត្តិធម៌នៃតុលាការ Yuan ត្រូវតែត្រូវបានបញ្ជាក់ដោយនីតិប្បញ្ញត្តិ។ សមាជិកសភាជ្រើសរើសប្រធាននីតិប្បញ្ញត្តិ ឬវាគ្មិនពីក្នុងចំណោមជួររបស់ពួកគេ។

ដោយសារតួនាទីសំខាន់របស់ប្រធានាធិបតីក្នុងការបំពេញមុខងាររបស់រដ្ឋាភិបាល ពាក្យ «គណបក្សកាន់អំណាច» តំណាងឱ្យគណបក្សនយោបាយណាមួយកាន់កាប់ការិយាល័យប្រធានាធិបតី។ គណបក្ស Kuomintang បានកាន់តំណែងជាប្រធានាធិបតីនៅតៃវ៉ាន់ អស់រយៈពេលជាង ៥ទសវត្សរ៍ មុនពេលគណបក្សប្រជាធិបតេយ្យ Progressive បានឈ្នះការបោះឆ្នោតប្រធានាធិបតីឆ្នាំ២០០០ និងឆ្នាំ២០០៤។ KMT បានត្រលប់មកកាន់អំណាចវិញនៅឆ្នាំ២០០៨ និងឆ្នាំ២០១២។ DPP បានឈ្នះការបោះឆ្នោតប្រធានាធិបតីឆ្នាំ២០១៦ និងឆ្នាំ២០២០ ដែលជាការកត់សម្គាល់ការផ្លាស់ប្តូរអំណាចទីបីចាប់តាំងពីលទ្ធិប្រជាធិបតេយ្យរបស់ប្រទេស។

នៅក្នុងការបោះឆ្នោតនីតិកាលខែមករា ឆ្នាំ២០២០ គណបក្ស DPP ទទួលបាន ៥៤ភាគរយនៃអាសនៈនៅក្នុងសភា ខណៈដែល KMT ទទួលបាន ៣៤ភាគរយ។ គណបក្សធំៗផ្សេងទៀតដែលមានវត្តមាននៅក្នុងសភារួមមាន គណបក្សប្រជាជនតៃវ៉ាន់ និងគណបក្សអំណាចថ្មី។[28]

[28] គេហទំព័រ៖ https://www.taiwan.gov.tw/content_4.php ចូលមើលចុងក្រោយ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣ ។

# ជំពូកទី២

# ការទទួលស្គាល់រដ្ឋ

# នៅក្នុងនីតិអន្តរជាតិ

# ជំពូកទី២

# ការទទួលស្គាល់រដ្ឋ នៅក្នុងនីតិអន្តរជាតិ

សហគមន៍អន្តរជាតិ គឺជាទីកន្លែងដែលបណ្តារដ្ឋរស់នៅជាមួយគ្នា និងមានទំនាក់ទំនងគ្នាទៅវិញទៅមក។ ប្រវត្តិសាស្ត្របង្ហាញថាអត្តសញ្ញាណ និងចំនួនរដ្ឋដែលរស់នៅក្នុងសហគមន៍អន្តរជាតិ តែងមានការប្រែប្រួល។ មានន័យថា រដ្ឋខ្លះបានបាត់រូបរាងក្នុងសហគមន៍អន្តរជាតិ ចំណែករដ្ឋខ្លះទៀតបានចាប់កំណើតនិងត្រូវបានទទួលស្គាល់ថ្មី។ ប្រទេសដែលធ្លាប់ស្ថិតក្រោមអាណានិគមរដ្ឋបរទេស បានទទួលភាពជារដ្ឋ។ ជាក់ស្តែង សហភាពសូវៀត ដែលត្រូវបានដួលរលំដោយបញ្ហាសេដ្ឋកិច្ច យោធា និងកត្តាផ្សេងៗទៀត ហើយបានធ្វើឱ្យរដ្ឋជាច្រើនបង្កើតជារដ្ឋឯករាជ្យ ឬជាប្រទេសថ្មី ឧទាហរណ៍ ហ្វាំងឡង់ ឡាតវី លីទុយអានី ប៉ូឡូញ ជាដើម។ ក្នុងនោះក៏មានប្រទេសរុស្ស៊ី ជាប្រទេសដ៏ធំមួយចាប់កំណើតថ្មីក្រោយសង្គ្រាមលោកលើកទី២ បន្ទាប់ពីសហភាសូវៀតដួលរលំ[29]។ ចំណែកប្រទេសមួយចំនួនទៀត ឧទាហរណ៍ព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រឡាវ ត្រូវបានប្រកាសឯករាជ្យ និងទទួលស្គាល់ភាពជារដ្ឋ បន្ទាប់ពីមានការដួលរលំនៃការដាក់អាណានិគមរបស់ប្រទេសបារាំងនៅអាស៊ីអាគ្នេយ៍[30]។ សូម្បីតែក្នុងករណីរដ្ឋដែលមានស្រាប់ ក៏ដូចជាបដិវត្តន៍ ឬព្រឹត្តិការណ៍មួយចំនួនកើតឡើងនាំឱ្យមានរដ្ឋាភិបាលថ្មីកើតឡើង ហើយនាំឱ្យមានការកើតឡើងជាបញ្ហាពាក់ព័ន្ធនឹងការទទួលស្គាល់រដ្ឋាភិបាលថ្មីដែលជំនួសរដ្ឋាភិបាលចាស់។ ករណីទាំងនេះ នាំឱ្យរដ្ឋនីមួយៗ ត្រូវសម្រេចចិត្តថា តើគួរទទួលស្គាល់រដ្ឋ ឬរដ្ឋាភិបាលថ្មី ឬយ៉ាងណា។ ការទទួលស្គាល់រដ្ឋ ឬរដ្ឋាភិបាល ពាក់ព័ន្ធទៅនឹងផលវិបាកផ្នែកច្បាប់ទាំងក្នុង និងក្រៅប្រទេស។ បញ្ហាប្រឈមជាក់ស្តែងក្នុងពេលបច្ចុប្បន្ន នៅឯប្រទេសមីយ៉ាន់ម៉ា ក៏មានការបង្កើតថ្មីនូវរដ្ឋាភិបាលស្រមោល និងមានរដ្ឋាភិបាលចាស់ដឹកនាំដោយយោធាដែលមានអំណាចក្នុងប្រទេស។ ស្ថានភាពនៅមីយ៉ាន់ម៉ានេះក៏ជាកត្តាធំជះឥទ្ធិពលដល់បញ្ហាក្នុងតំបន់អាស៊ានដែលពុំអាចខ្វះបានក្នុងការប្រជុំកំពូលម្តងៗ មានការលើកឡើងអំពីការផ្តល់កៅអីទៅឱ្យភាគីខាងណាតំណាងឱ្យប្រទេសមីយ៉ាន់ម៉ា។ ក្នុងករណីនៃដែនកោះតៃវ៉ាន់ និងប្រទេសចិនវិញជាការពិតណាស់ បើយើងវិលទៅមើលប្រវត្តិនៃអតីតកាល កោះតៃវ៉ាន់ត្រូវបានគេទទួលស្គាល់ និងត្រូវបានផ្តល់កៅអីនៅក្នុងអង្គការសហប្រជាជាតិ តែក្នុងលក្ខខណ្ឌឬក្នុងក្របខណ្ឌនៃការជំនួសរដ្ឋាភិបាលចិនដោយរដ្ឋាភិបាល

---

[29] គេហទំព័រ៖ https://encyclopedia.1914-1918-online.net/article/post-war_economies_east_central_europe#:~:text=After%20World%20War%20I%2C%20five,Latvia%2C%20Lithuania%2C%20and%20Poland និងគេហទំព័រ៖ https://www.britannica.com/story/25th-anniversary-of-the-end-of-the-soviet-union ចូលមើលចុងក្រោយ ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៣។

[30] គេហទំព័រ៖ https://peacemaker.un.org/sites/peacemaker.un.org/files/KH-LA-VN_540720_GenevaAgreements.pdf ចូលមើលចុងក្រោយ ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៣។

កោះតៃវ៉ាន់ប៉ុណ្ណោះ រហូតមកទល់នឹងពេលក្រោយរដ្ឋាភិបាលចិនក៏ត្រូវបានជំនួសកៅអីចាស់របស់ខ្លួនវិញនៅក្នុងស្ថាប័នអន្តរជាតិមួយនេះ។

ជាទូទៅក្នុងការទទួលស្គាល់រដ្ឋមួយគេត្រូវសិក្សាឬដាក់ជាសំនួរដូចតទៅ៖ «តើការទទួលស្គាល់គឺជាអ្វី? តើមូលហេតុអ្វីបានជាត្រូវទទួលស្គាល់? តើការទទួលស្គាល់ ត្រូវធ្វើឡើងដូចម្តេច? តើការទទួលស្គាល់មានប្រភេទ និងទម្រង់ដូចម្តេចខ្លះ? តើការទទួលស្គាល់នាំមកនូវផលវិបាកអ្វីខ្លះ?»

## ២.១ និយមន័យ និងមូលហេតុនៃការទទួលស្គាល់

ការទទួលស្គាល់ គឺជាកិច្ចឯកតោភាគីដែលអនុវត្តដោយរដ្ឋាភិបាលនៃរដ្ឋមួយ ដែលទទួលស្គាល់ជាផ្លូវការនូវអត្ថិភាពនៃរដ្ឋ ឬរដ្ឋាភិបាល ឬក្រុមប្រឆាំងរដ្ឋាភិបាលណាមួយ។ ការទទួលស្គាល់អង្គភាពទាំងនេះ គឺជាបញ្ហាដ៏ស្មុគស្មាញមួយនៃច្បាប់អន្តរជាតិព្រោះវាពាក់ព័ន្ធទៅនឹងបញ្ហានយោបាយ ច្បាប់ជាតិ និងច្បាប់អន្តរជាតិ។

ការទទួលស្គាល់រដ្ឋ គឺជាកិច្ចឯកតោភាគី និងជាឆន្ទានុសិទ្ធិ ដែលតាមរយនេះ រដ្ឋមួយប្រកាន់គោលជំហរណាមួយ ចំពោះស្ថានការណ៍ណាមួយ ឬព្រឹត្តិការណ៍ណាមួយដែលកើតឡើងក្តៅខ្លួន។[31] ការទទួលស្គាល់រដ្ឋគឺជាកាតព្វកិច្ចចាំបាច់របស់រដ្ឋមួយ ក្នុងឋានៈរដ្ឋជាសមាជិកមួយរបស់សហគមន៍អន្តរជាតិ។

ការទទួលស្គាល់រដ្ឋ ដោយរដ្ឋមួយផ្សេងទៀត គឺជាការឆ្លុះបញ្ចាំងឱ្យឃើញថា រដ្ឋនោះមានសិទ្ធិ និងសមត្ថកិច្ចគ្រប់បែបយ៉ាង ដើម្បីធ្វើទំនាក់ទំនងអន្តរជាតិតាមផ្លូវច្បាប់ជាមួយរដ្ឋដែលបានទទួលស្គាល់នោះ។[32] ការកំណត់និយមន័យនៃការទទួលស្គាល់រដ្ឋ គឺជាការទទួលស្គាល់ជាឆន្ទៈមួយ ដើម្បីទទួលរដ្ឋថ្មីនោះ ឱ្យក្លាយទៅជាសមាជិកមួយនៃសហគមន៍អន្តរជាតិ។[33]

ការទទួលស្គាល់រដ្ឋ គឺជាកិច្ចមួយដែលតាមរយៈនេះ រដ្ឋមួយអាចបញ្ជាក់ថាអត្ថិភាពរបស់រដ្ឋណាមួយទៀតមានពិតប្រាកដ និងជាក់ច្បាស់ ហើយដោយហេតុផលនេះ គាត់មានឆន្ទៈចាត់ទុករដ្ឋនោះ ជាសមាជិកមួយដែរនៃសង្គមអន្តរជាតិ ដូចជាគាត់យល់ព្រមបង្កើតទំនាក់ទំនងការទូតជាដើម។[34] ការទទួលស្គាល់រដ្ឋមួយ គឺជាសកម្មភាពនយោបាយជាឯកតោភាគីរបស់រដ្ឋនីមួយៗហើយក៏គ្មានរដ្ឋណាមួយបង្ខិតបង្ខំឱ្យរដ្ឋមួយទៀតទទួលស្គាល់រដ្ឋដទៃដែរ។

[31] អ៊ឹង រដ្ឋា, នីតិអន្តរជាតិសាធារណៈ, បោះពុម្ពលើកទី៦(ភ្នំពេញ, ២០១២),ទំព័រទី ១៥៩

[32] ជុំ អ៊ុម, ទំនាក់ទំនងអន្តរជាតិ, បោះពុម្ពលើកទី២(ភ្នំពេញ ៖ រោងពុម្ពជោគជ័យ, ២០១១), ទំព័រទី ១៥៩

[33] ខៀវ ថវិកា, នីតិអន្តរជាតិសាធារណៈ, បោះពុម្ពលើកទី១(ភ្នំពេញ ៖ គីម សួគ៌, ២០១០), ទំព័រទី ១០៥

[34] អ៊ឹង រដ្ឋា, នីតិអន្តរជាតិសាធារណៈ, បោះពុម្ពលើកទី៦(ភ្នំពេញ, ២០១២) ទំព័រទី ១៥៩

បញ្ហានៃការទទួលស្គាល់ គឺពាក់ព័ន្ធទៅនឹងរឿងនយោបាយ ច្រើនជាងច្បាប់។[35] ទង្វើរបស់រដ្ឋដែលទទួលស្គាល់ តែងតែផ្អែកទៅលើផលប្រយោជន៍ជាតិខ្លួន ដែលនៅភ្ជាប់គ្នាជាមួយនឹងកិច្ចរក្សាទំនាក់ទំនងជាមួយនឹងរដ្ឋ ឬរដ្ឋាភិបាលថ្មី។ ទោះជាយ៉ាងនេះក្តី ការទទួលស្គាល់ត្រូវតែផ្អែកទៅលើគោលការណ៍ច្បាប់ផងដែរ ព្រោះថាការទទួលស្គាល់ត្រូវបានចាត់ទុកថាជាសកម្មភាពនយោបាយដែលមានផលវិបាកផ្នែកច្បាប់។

ជាទូទៅ ការទទួលស្គាល់តែងតែធ្វើឡើងក្នុងទម្រង់ជាកិច្ចឯកតោភាគីផ្លូវទូត ហើយសហគមន៍អន្តរជាតិមិនមានកំណត់នីតិវិធីតម្រូវណាមួយជាក់លាក់នោះទេ។ ការទទួលស្គាល់អាចជា៖

- ការទទួលស្គាល់រដ្ឋថ្មី
- ការទទួលស្គាល់រដ្ឋាភិបាលថ្មី
- ការទទួលស្គាល់ក្រុមបះបោរ (belligerency)។

លើសពីនេះ ការទទួលស្គាល់អាចជាការទទួលស្គាល់តាមផ្លូវច្បាប់ (de jure recognition) ការទទួលស្គាល់តាមព្រឹត្តិន័យ (de facto recognition) ការទទួលស្គាល់មានលក្ខខណ្ឌ (conditional recognition) ការទទួលស្គាល់ដោយស្ងៀមស្ងាត់ (implied recognition) និងការទទួលស្គាល់ដោយពាក្យពេចន៍ (express recognition)។

មូលហេតុទាំងឡាយដែលជាមូលដ្ឋានក្នុងការសម្រេចចិត្តទទួលស្គាល់រដ្ឋមួយមានច្រើនករណី ដូចជាសារសំខាន់ខាងវិស័យពាណិជ្ជកម្ម ទំនាក់ទំនងទៅនឹងនយោបាយក្នុងប្រទេស ទំនាក់ទំនងជាមួយនឹងសម្ព័ន្ធមិត្តខាងយោធា ហេតុផលមនុស្សធម៌ និងការធ្វើទំនាក់ទំនងខាងផ្លូវទូត។

ហេតុផលទាំងឡាយសម្រាប់ការសម្រេចទទួលស្គាល់រដ្ឋមួយមានច្រើនករណី ដូចជា សារៈសំខាន់ខាងសម្ព័ន្ធភាព វិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិទ្យាសាស្ត្រ នយោបាយ វប្បធម៌ ទំនាក់ទំនង ការទូត ហេតុផលនៃវិស័យមនុស្សធម៌ និងផលប្រយោជន៍ដទៃទៀត។ ការទទួលស្គាល់រដ្ឋ គឺជា ប្រធានបទមួយដ៏ពិបាកជាងគេ នៅក្នុងនីតិអន្តរជាតិ ពីព្រោះបញ្ហានេះជាបញ្ហាប្រទាក់ក្រឡាគ្នានៅ ក្នុងវិស័យនយោបាយ វិស័យនីតិអន្តរជាតិ និងនីតិក្នុងប្រទេស។ ការទទួលស្គាល់រដ្ឋមួយអាចដំណើរការទៅបានទៅតាមលក្ខណៈដូចជា ការចាប់កំណើតនៃរដ្ឋថ្មីមួយ ការបង្កើតរដ្ឋាភិបាលថ្មីនិងការប្រែប្រួលខាងទឹកដី។[36] ជាទូទៅ ការទទួលស្គាល់រដ្ឋកើតមានឡើងនៅពេលដែលរដ្ឋមួយមានការផ្លាស់ប្តូរទឹកដីក្នុងនោះរួមមានទិដ្ឋភាពដូចតទៅ៖

ទឹកដីឧត្តរាធិការ ទឹកដីរដ្ឋមួយបានទទួលមរតកពីរដ្ឋមួយផ្សេងទៀត។ ឧទាហរណ៍៖ ទឹកដី ប្រទេសរុស្ស៊ីបានបន្តមកពីអតីតរដ្ឋសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត។

---

[35] គេហទំព័រ៖ https://blog.ipleaders.in/state-recognition/ ចូលមើលចុងក្រោយ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២។

[36] នួន សុធិមន្ត. ទំនាក់ទំនងអន្តរជាតិ, បោះពុម្ព(ភ្នំពេញ ៖ បណ្ណាគារ អង្គធំ, ២០០៧), ទំព័រទី ៤៣ ដល់ទំព័រទី៤៤

ទឹកដីអបគមន៍ មានន័យថា រដ្ឋមួយថ្មីត្រូវបានបង្កើតឡើងអាស្រ័យដោយបំបែកចេញពីទឹកដី នៃរដ្ឋចាស់។ ឧទាហរណ៍ ទឹកដីប្រទេសអាមេនី បានបំបែកចេញពីទឹកដីអតីតសហភាព សាធារណរដ្ឋសង្គមនិយមសូវៀត។

ទឹកដីដែលមានលក្ខណៈស្វ័យភាពខាងការគ្រប់គ្រង មានន័យថាប្រជាជាតិមួយដែលពីមុន នៅក្រោមការត្រួតត្រាពីបរទេស ហើយទើបទទួលបានស្វ័យភាពក្នុងការគ្រប់គ្រងដោយខ្លួនឯង។ ករណីទឹកដីកោះទីម័រខាងកើត ដែលទើបនឹងទទួលបានឯករាជ្យពេញលេញនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០២។

រដ្ឋមួយដែលត្រូវបានសហគមន៍អន្តរជាតិទទួលស្គាល់ ចាំបាច់ត្រូវមានលក្ខខណ្ឌមួយចំនួនដូចជា៖

- មានការរៀបចំនយោបាយមួយជាក់លាក់
- មានការគ្រប់គ្រងលើដែនដីទាំងមូលជាអចិន្ត្រៃយ៍
- មានឯករាជ្យភាព

រួមផ្សំទៅដោយធាតុសំខាន់ៗរបស់រដ្ឋ ដូចជា ទឹកដី ប្រជាពលរដ្ឋ រដ្ឋាភិបាល និងអធិបតេយ្យភាព មិនស្ថិតនៅក្រោមការត្រួតត្រារបស់ប្រទេសដទៃ។[37]

## ២.២ ប្រភេទ និងទម្រង់នៃការទទួលស្គាល់

ការទទួលស្គាល់មានច្រើនប្រភេទ ដែលទាំងនោះអាចជា ការទទួលស្គាល់រដ្ឋថ្មី ការទទួលស្គាល់រដ្ឋាភិបាលថ្មី ឬការទទួលស្គាល់ក្រុមបះបោរ ហើយក្រៅពីនេះគេអាចទទួលស្គាល់អង្គភាពផ្សេងៗទៀតផងដែរ។ ការទទួលស្គាល់អាចមានទម្រង់ផ្សេងៗ ដូចជា៖[38]

- ការទទួលស្គាល់ផ្លូវច្បាប់ ឬតាមព្រឹត្តិន័យ
- ការទទួលស្គាល់ដោយពាក្យពេចន៍ ឬដោយតុណ្ហីភាព និងអាចជា
- កិច្ចមានលក្ខខណ្ឌ (conditional)

### ២.២.១ ការទទួលស្គាល់រដ្ឋ និងរដ្ឋាភិបាល

នៅពេលដែលមានការចាប់បដិសន្ធិរដ្ឋថ្មីមួយ នោះរដ្ឋដទៃទៀតនឹងត្រូវពិចារណាថា «តើទទួលស្គាល់ឬមិនទទួលស្គាល់?»។ ការទទួលស្គាល់មានន័យថាការបង្ហាញឆន្ទៈរបស់រដ្ឋទទួលស្គាល់ទំនាក់ទំនងជាមួយរដ្ឋថ្មី

[37] នួន សុធិមន្ត. ទំនាក់ទំនងអន្តរជាតិ, បោះពុម្ព(ភ្នំពេញ ៖ បណ្ណាគារ អង្គធំ, ២០០៧), ទំព័រទី ៤៣

[38] គេហទំព័រ៖ https://law2021.wordpress.com/2021/12/20/state-recognition/#%E1%9F%A3.-%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%97%E1%9F%81%E1%9E%91-%E1%9E%93%E1%9E%B7%E1%9E%84%E1%9E%91%E1%9E%98%E1%9F%92%E1%9E%9A%E1%9E%84%E1%9F%8B%E1%9E%93%E1%9F%83%E1%9E%80%E1%9E%B6%E1%9E%9A%E1%9E%91%E1%9E%91%E1%9E%BD%E1%9E%9B%E1%9E%9F%E1%9F%92%E1%9E%82%E1%9E%B6%E1%9E%9B%E1%9F%8B ចូលមើលចុងក្រោយ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២។

ក្នុងនាមជាសមាជិកសហគមន៍អន្តរជាតិ។ ដើម្បីផ្តល់ការទទួលស្គាល់ដល់អង្គភាពថ្មីមួយ អង្គភាពនោះត្រូវបំពេញនូវតម្រូវការមូលដ្ឋាននៃភាពជារដ្ឋ។

ការទទួលស្គាល់រដ្ឋមួយ មានន័យថាជាការផ្តល់សមាជិកភាពដល់រដ្ឋនោះទៅក្នុងសហគមន៍អន្តរជាតិ ហើយជាលទ្ធផលរដ្ឋថ្មីនោះនឹងទទួលបានបុគ្គលភាពគតិយុត្តអន្តរជាតិ។ ការទទួលស្គាល់ ជាការអនុញ្ញាតឱ្យរដ្ឋដែលត្រូវបានទទួលស្គាល់អនុវត្តសិទ្ធិ និងកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិ។ ការទទួលស្គាល់រដ្ឋថ្មី មានការពាក់ព័ន្ធដោយស្វ័យប្រវត្តិទៅនឹងការទទួលស្គាល់រដ្ឋាភិបាលនៃរដ្ឋនោះ។

ការទទួលស្គាល់រដ្ឋាភិបាលថ្មី មានភាពដាច់ដោយឡែកពីការទទួលស្គាល់រដ្ឋាភិបាល ទោះបីជាក្នុងគោលការណ៍ ភាគច្រើនគេចាត់ទុកថាការទទួលស្គាល់ទាំងពីរប្រភេទនេះអនុវត្តគោលការណ៍ច្បាប់ និងនយោបាយដូចគ្នាក្តី។ ចំពោះរដ្ឋការទទួលស្គាល់ត្រូវឆ្លងកាត់ការពិចារណាលើការបំពេញបាននូវតម្រូវការមូលដ្ឋាននៃភាពជារដ្ឋ ចំណែកការទទួលស្គាល់រដ្ឋាភិបាល គេនឹងពិចារណាលើលក្ខខណ្ឌសំខាន់ពីរគឺប្រសិទ្ធភាព និងភាពឯករាជ្យ។

គួរកត់សម្គាល់ថា អត្ថិភាពនៃរដ្ឋាភិបាលដែលមានប្រសិទ្ធិភាពនិងឯករាជ្យភាព គឺជាខ្លឹមដ៏សំខាន់ដើម្បីទទួលបានភាពជារដ្ឋ។ តាមរយៈការទទួលស្គាល់រដ្ឋាភិបាល រដ្ឋដែលទទួលស្គាល់ទទួលយកកិច្ចទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាល ដូចជាអាជ្ញាធររដ្ឋ ហើយរដ្ឋទទួលស្គាល់នោះនឹងផ្តល់នូវបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិស្របតាមប្រព័ន្ធច្បាប់ផ្ទៃក្នុងរបស់ខ្លួន។

ការផ្តល់ ឬមិនផ្តល់ការទទួលស្គាល់ មិនមានឥទ្ធិពលឡើយទៅលើការទទួលស្គាល់រដ្ឋ។ ការទទួលស្គាល់រដ្ឋមានឥទ្ធិពលដល់បុគ្គលភាពគតិយុត្តរបស់រដ្ឋ ខណៈដែលការទទួលស្គាល់រដ្ឋាភិបាលមានឥទ្ធិពលដល់ឋានៈរបស់រដ្ឋាភិបាលក្នុងក្នុងនាមជាអាជ្ញាធររបស់រដ្ឋ មិនមែនជាការទទួលស្គាល់ឋានៈជារដ្ឋឡើយ។ ករណីនេះ រដ្ឋាភិបាលបន្តបន្ទាប់ទៀតអាចមិនត្រូវបានទទួលស្គាល់។ ក៏ប៉ុន្តែ ការទទួលស្គាល់រដ្ឋមានលក្ខណៈអចិន្ត្រៃយ៍ ពោលគឺនៅពេលដែលរដ្ឋថ្មីត្រូវបានទទួលស្គាល់ វានឹងទទួលបានបុគ្គលភាពគតិយុត្តក្រោមច្បាប់អន្តរជាតិជារៀងរហូត។ ប្រសិនបើរដ្ឋាភិបាលរបស់រដ្ឋមានការផ្លាស់ប្តូរ ស្របតាមនីតិវិធីកំណត់ដោយរដ្ឋធម្មនុញ្ញរបស់រដ្ឋនោះ នោះនឹងមិនមានបញ្ហាអ្វីកើតឡើងឡើយ ព្រោះថារដ្ឋាភិបាលនោះទទួលបានអំណាចត្រឹមត្រូវ និងរក្សាបានស្ថិរភាពផ្ទៃក្នុង។ ក្នុងករណីនេះ ការទទួលស្គាល់រដ្ឋាភិបាលដោយរដ្ឋដទៃទៀត ធ្វើឡើងដើម្បីបំពេញលក្ខខណ្ឌទម្រង់តែប៉ុណ្ណោះ។ បញ្ហាទទួលស្គាល់រដ្ឋាភិបាលថ្មីកើតឡើងនៅពេលដែល មានការផ្លាស់ប្តូរមិនស្របទៅនឹងរដ្ឋធម្មនុញ្ញ ឬមានបដិវត្តន៍។ ការទទួលស្គាល់រដ្ឋាភិបាលបដិវត្តន៍ គឺជាបញ្ហាដ៏លំបាកមួយ ហើយការសម្រេចចិត្តទទួលស្គាល់ ឬមិនទទួលស្គាល់ ត្រូវធ្វើឡើងដោយប្រុងប្រយ័ត្នបំផុត។

**២.២.២ ការទទួលស្គាល់ក្រុមបះបោរ** (Recognition of Belligerency)

នៅពេលដែលផ្នែកមួយនៃទឹកដី និងប្រជាជនរបស់រដ្ឋស្ថិតក្រោមការគ្រប់គ្រងដោយក្រុមបះបោរប្រឆាំង នោះក្រុមប្រឆាំងអាចនឹងទាមទារបំបែករដ្ឋមួយដាច់ដោយឡែក ឬក៏តស៊ូផ្តួលរំលំ រដ្ឋាភិបាលដែលមានស្រាប់។ ដើម្បីទទួលបានការទទួលស្គាល់ ក្រុមបះបោរត្រូវមានអង្គភាពនយោបាយមួយដែលអាចអនុវត្តន៍ការគ្រប់គ្រង និងទទួលបានការគាំទ្រពីប្រជាជនក្នុងចំនួនសមស្រប ហើយត្រូវប្រព្រឹត្តដោយអនុលោមតាមច្បាប់សង្គ្រាម។ ដូច្នេះ ការទទួលស្គាល់ក្រុមបះបោរ គឺជាការទទួលស្គាល់ជាផ្លូវការដោយរដ្ឋភាគីទីបី អំពីអត្ថិភាពសង្គ្រាមរវាងរដ្ឋាភិបាលកណ្តាល ជាមួយនឹងផ្នែកមួយនៃរដ្ឋ។ នេះបញ្ជាក់ថា រដ្ឋទីបី ដែលទទួលស្គាល់ថាក្រុមបះបោរទទួលបានសិទ្ធិ និងកាតព្វកិច្ចក្រោមច្បាប់សង្គ្រាម។ ជាការពិតណាស់ចំពោះការទទួលស្គាល់ក្រុមបះបោរ ពុំមានការទាក់ទងគ្នានឹងប្រធានបទនៃសារណាទេ ហេតុនេះសូមធ្វើការបកស្រាយដោយខ្លី នឹងឈានចូលទៅចំណុចផ្សេងៗទៀតដែលជាចំណុចសំខាន់។

**២.២.៣ ការទទួលស្គាល់ តាមផ្លូវច្បាប់ និង តាមព្រឹត្តិន័យ**

ការអនុវត្តរបស់រដ្ឋ បានបង្ហាញពីភាពខុសគ្នារវាងការទទួលស្គាល់តាមច្បាប់ (de jure recognition) និងការទទួលស្គាល់តាមព្រឹត្តិន័យ (de facto recognition)។ ភាពខុសគ្នានេះកើតឡើងក្នុងករណីទទួលស្គាល់រដ្ឋាភិបាល ខណៈដែលការទទួលស្គាល់រដ្ឋអាចធ្វើឡើងភាគច្រើនតាមច្បាប់ ទោះបីជាមានករណីតិចតួចមានការទទួលស្គាល់រដ្ឋតាមព្រឹត្តិន័យ។ ករណី ប្រទេសឥណ្ឌូនេស៊ី ត្រូវបានទទួលស្គាល់ដោយរដ្ឋមួយចំនួន នៅក្នុងកំឡុងពេលដែលខ្លួនកំពុងប្រយុទ្ធទាមទារឯករាជ្យប្រឆាំងនឹងប្រទេសហូឡង់អំឡុងឆ្នាំ១៩៤៥ ដល់ឆ្នាំ១៩៥៩។

ការទទួលស្គាល់តាមច្បាប់ មានន័យថា រដ្ឋដែលទទួលស្គាល់រដ្ឋ ឬរដ្ឋាភិបាលណាមួយ ផ្អែកលើការបំពេញបានតាមលក្ខខណ្ឌតម្រូវក្រោមច្បាប់អន្តរជាតិ។ ការទទួលស្គាល់តាមព្រឹត្តិន័យថា ក្នុងគំនិតរបស់រដ្ឋដែលទទួលស្គាល់ យល់ថារដ្ឋ ឬរដ្ឋាភិបាលដែលខ្លួនទទួលស្គាល់និងបំពេញបាននូវលក្ខខណ្ឌតម្រូវក្រោមច្បាប់អន្តរជាតិ។ ដូច្នេះការទទួលស្គាល់តាមព្រឹត្តិន័យមានលក្ខណៈបណ្តោះអាសន្ន ហើយអាចត្រូវបានដកចេញនៅពេលអនាគត។

ការទទួលស្គាល់រដ្ឋាភិបាលមួយតាមព្រឹត្តិន័យ បង្ហាញថាមានការសង្ស័យអំពីស្ថិរភាព និងលទ្ធភាពទទួលបានជោគជ័យរបស់រដ្ឋាភិបាលនោះ។ ការទទួលស្គាល់តាមព្រឹត្តិន័យពាក់ព័ន្ធទៅនឹងជំហរដែលស្ទាក់ស្ទើរដោយរដ្ឋទទួលស្គាល់ ដោយប្រើអាកប្បកិរិយារង់ចាំមើល ដែលជាទូទៅនឹងបំប្លែងជាការទទួលស្គាល់តាមច្បាប់ នៅពេលដែលរដ្ឋទទួលស្គាល់យល់ឃើញថា រដ្ឋាភិបាលនោះបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។

ការទទួលស្គាល់តាមព្រឹត្តិន័យ អាចជាដំណាក់កាលដំបូងមុននឹងមានការទទួលស្គាល់តាមច្បាប់ ជាពិសេសក្នុងករណីដែលរដ្ឋាភិបាលឡើងកាន់អំណាចដោយមិនស្របតាមរដ្ឋធម្មនុញ្ញ។ ក្នុងករណីបែបនេះ ការទទួលស្គាល់តាមព្រឹត្តិន័យ គឺជាកិច្ចដែលមិនមានការប្តេជ្ញាចិត្តដែលរដ្ឋទទួលស្គាល់ យល់ថាមានរដ្ឋាភិបាលតាមព្រឹត្តិន័យ

កំពុងកាន់កាប់អំណាចអធិបតេយ្យតាមព្រឹត្តិន័យ ប៉ុន្តែការកាន់កាប់នោះអាចនឹងខុសច្បាប់ គ្មានស្ថិរភាព ឬមិនអចិន្ត្រៃយ៍។ នៅដំណាក់កាលបន្ទាប់ នៅពេលដែលការស្ទាក់ស្ទើរត្រូវបានបញ្ចប់ដោយសារថា រដ្ឋាភិបាលតាមព្រឹត្តិន័យធានាបានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពអចិន្ត្រៃយ៍ នឹងមានការទទួលស្គាល់តាមច្បាប់។ ជាក់ស្តែងអង់គ្លេសបានទទួលស្គាល់រដ្ឋាភិបាលសូវៀតតាមព្រឹត្តិន័យនៅឆ្នាំ១៩២១ ហើយក្រោយមកទៀត ទទួលស្គាល់តាមច្បាប់នៅឆ្នាំ១៩២៤។

ក្នុងកំឡុងសង្គ្រាមស៊ីវិលអេស្ប៉ាញ (១៩៣៦-១៩៣៩) អង់គ្លេសបានផ្តល់ការទទួលស្គាល់គូរបដិបក្ខសង្គ្រាមទាំងពីរ គឺទទួលស្គាល់តាមច្បាប់ចំពោះរដ្ឋាភិបាលសាធារណរដ្ឋ និងទទួលស្គាល់តាមព្រឹត្តិន័យចំពោះរដ្ឋាភិបាលរបស់ឧត្តមសេនីយ៍ប្រាង់កូ (General Franco) ដែលបានកាន់កាប់ទឹកដីស្ទើរទាំងអស់ ហើយក្រោយមកក៏ទទួលស្គាល់រដ្ឋាភិបាលប្រាង់កូតាមច្បាប់វិញ។ នៅកំឡុងឆ្នាំ១៩៨៨-១៩៩១ រដ្ឋភាគច្រើនទទួលស្គាល់រដ្ឋាភិបាលបដិបក្ខទាំងពីរនៅឡេបាណុន (Lebanon) តាមព្រឹត្តិន័យ រហូតដល់ការបះបោរដឹកនាំដោយ ឧត្តមសេនីយ៍ អោន (General Aoun) ត្រូវបានបញ្ចប់ ហើយរដ្ឋាភិបាលរបស់លោក សាលីម អាល់ហុស (Salim Al Huss) ត្រូវបានទទួលស្គាល់តាមច្បាប់។

នៅពេលដែលការទទួលស្គាល់ត្រូវបានធ្វើឡើងដោយសេចក្តីថ្លែងការណ៍ វាអាចត្រូវបានចាត់ទុកថាជាការទទួលស្គាល់តាមច្បាប់ លើកលែងតែរដ្ឋដែលទទួលស្គាល់នោះបានកំណត់ផ្សេងពីនេះ។ នៅពេលដែលការទទួលស្គាល់ ជាកិច្ចស្ងៀមស្ងាត់នោះ តែងតែមានភាពមិនច្បាស់លាស់អំពីឆន្ទៈរបស់រដ្ឋដែលទទួលស្គាល់នោះថាទទួលស្គាល់តាមច្បាប់ ឬតាមព្រឹត្តិន័យ។

ទោះបីជាមានមូលដ្ឋានខុសគ្នាខ្លះក្តី ប៉ុន្តែប្រសិទ្ធភាពនៃការទទួលស្គាល់ទាំងពីរប្រភេទខាងលើស្ទើរតែដូចគ្នាទាំងស្រុង។

### ២.២.៤ ការទទួលស្គាល់ជា លាយលក្ខណ៍អក្សរ និងដោយស្ងៀមស្ងាត់

ការទទួលស្គាល់គឺជាបញ្ហាឆន្ទៈ និងចេតនារបស់រដ្ឋ ដែលរដ្ឋអាចបង្ហាញការទទួលស្គាល់ជាលាយលក្ខណ៍អក្សរ (Express) ឬតាមរយៈភាពស្ងៀមស្ងាត់ (imply)។ ការទទួលស្គាល់ជាលាយលក្ខណ៍អក្សរគឺជាការបង្ហាញការទទួលស្គាល់រដ្ឋណាមួយ ធ្វើឡើងក្រោមរូបភាពជាសេចក្តីថ្លែងការណ៍ ទទួលស្គាល់ជាសាធារណៈ ឬអាចជាសារបញ្ជូនផ្ទាល់ពីប្រមុខរដ្ឋឬរដ្ឋមន្ត្រីការបរទេស ឬតាមរយៈកំណត់ទូត ឬអាចជាសន្ធិសញ្ញាស្តីពីការទទួលស្គាល់។

ប៉ុន្តែ មិនមែនមានន័យថាការទទួលស្គាល់ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរនោះទេ ដែលករណីខ្លះការទទួលស្គាល់អាចបង្ហាញតាមរយៈភាពស្ងៀមស្ងាត់របស់រដ្ឋ។ ការទទួលស្គាល់ដោយស្ងៀមស្ងាត់ គឺជាការទទួលស្គាល់រដ្ឋ ឬរដ្ឋាភិបាលតាមរយៈសកម្មភាពមិនលាយលក្ខអក្សរ ដែលមានឆន្ទៈបង្ហាញការទទួលស្គាល់។

សកម្មភាពបង្ហាញការទទួលស្គាល់បែបនេះ ត្រូវតែច្បាស់លាស់ មិនមានភាពសង្ស័យ។ សកម្មភាពខ្លះអាចចាត់ទុកថា ជាការទទួលស្គាល់ដោយស្ងៀមស្ងាត់ ដូចជាសេចក្តីថ្លែងការណ៍អបអរសាទរការទទួលបានឯករាជ្យ ការបង្កើតទំនាក់ទំនងការទូតផ្លូវការ និងការចុះសន្ធិសញ្ញាទ្វេភាគីជាដើម។ ចំណែកសកម្មភាពខ្លះទៀតមិនអាចចាត់ទុកថាជាការទទួលស្គាល់នោះទេ ដែលទាំងនោះមានដូចជា ការចូលរួមក្នុងសន្និសញ្ញាពហុភាគី សមាជិកភាពនៃអង្គការអន្តរជាតិជាមួយគ្នា ការចូលរួមក្នុងសន្និសីទអន្តរជាតិជាមួយគ្នា ការរក្សាទំនាក់ទំនងក្រៅផ្លូវការ ការផ្តួចផ្តើមការចរចាជាមួយរដ្ឋដែលមិនត្រូវបានទទួលស្គាល់ និងការតវ៉ាប្រឆាំងនឹងរដ្ឋមិនត្រូវបានទទួលស្គាល់។

### ២.២.៥ ការទទួលស្គាល់មានលក្ខខណ្ឌ

ពេលខ្លះរដ្ឋមួយអាចត្រូវបានទទួលស្គាល់ ក្រោមលក្ខខណ្ឌជាក់លាក់ ដែលជាទូទៅលក្ខខណ្ឌពាក់ព័ន្ធដល់បំពេញកាតព្វកិច្ចមួយចំនួន។ ដូចជាករណី ការកំណត់លក្ខខណ្ឌឱ្យគោរព និងធានាសិទ្ធិក្រុមជាតិពន្ធុក្រុមជនជាតិភាគតិច ការគោរពសេរីភាពសាសនា ការគោរពវិធានច្បាប់ លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។

ការខកខានមិនបានបំពេញកាតព្វកិច្ច មិនអាចនាំទៅរកការមោឃភាពការទទួលស្គាល់ឡើយ ព្រោះថានៅពេលដែលរដ្ឋទទួលស្គាល់រដ្ឋណាមួយហើយ ការទទួលស្គាល់មិនអាចត្រូវបានដកវិញបានឡើយ។ ជំនួសករណីនេះ រដ្ឋដែលទទួលស្គាល់ អាចចោទរដ្ឋដែលត្រូវបានទទួលស្គាល់ហើយមិនបានបំពេញតាមលក្ខខណ្ឌថារំលោភច្បាប់អន្តរជាតិ និងអាចបង្ហាញការធ្លាក់ចុះទំនាក់ទំនងការទូតជាមួយរដ្ឋដែលមិនគោរពលក្ខខណ្ឌ។ ទោះជាយ៉ាងនេះក្តី ការទទួលស្គាល់មានលក្ខខណ្ឌនៃរដ្ឋ ឬរដ្ឋាភិបាល ដែលកំពុងដំណើរការបង្កើត ក្នុងករណីខ្លះអាចដកវិញបាន។

## ២.៣ វិបាកផ្លូវច្បាប់នៃការទទួលស្គាល់រដ្ឋ

ទោះបីជាការទទួលស្គាល់ គឺជាកិច្ចដែលមានលក្ខណៈនយោបាយក្តី ប៉ុន្តែវាអាចបង្កើតជាវិបាកគតិយុត្តសំខាន់ៗមួយចំនួន។ ការទទួលស្គាល់ មានវិបាកគតិយុត្តទាំងនៅកម្រិតអន្តរជាតិ និងកម្រិតជាតិ។ ប្រសិនបើអង្គភាពមួយត្រូវបានទទួលស្គាល់ថាជារដ្ឋ អង្គភាពនោះនឹងទទួលបានសិទ្ធិនិងកាតព្វកិច្ចពាក់ព័ន្ធ ព្រមទាំងទទួលបានបានបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិផងដែរ។

### ២.៣.១ វិបាកកម្រិតអន្តរជាតិនៃការទទួលស្គាល់

ការទទួលស្គាល់ មានការពាក់ព័ន្ធទៅនឹងការខ្វែងគំនិតគ្នារវាងទ្រឹស្តីពីរ គឺទ្រឹស្តីវិធានច្បាប់ (constitutive theory) និងទ្រឹស្តីជាក់ស្តែងនិយម (declaratory theory)។ ទ្រឹស្តីទទួលស្គាល់តាមច្បាប់ កំណត់ថារដ្ឋមួយត្រូវបានសហគមន៍អន្តរជាតិទទួលស្គាល់ គឺដោយសារថារដ្ឋបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់តាមច្បាប់អន្តរជាតិដើម្បីទទួលបានភាពជារដ្ឋ ពោលគឺមានប្រជាជន ទឹកដី មានរដ្ឋាភិបាលឯករាជ្យ និងមានអធិបតេយ្យពិតប្រាកដ។

ចំណែកទ្រឹស្តីជាក់ស្តែងនិយម កំណត់ថា រដ្ឋមួយមានអត្ថិភាពបាន ទោះបីជាគ្មានការទទួលស្គាល់ពីបណ្តារដ្ឋខ្លះក៏ដោយ ហើយក៏អាចទទួលស្គាល់ពីសំណាក់រដ្ឋខ្លះៗទៀតដែរ។

ការទទួលស្គាល់ គឺជាហេតុផលនាំឱ្យរដ្ឋមួយទទួលបានសិទ្ធិ និងកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិ។ ការទទួលស្គាល់រដ្ឋមួយ ដោយរដ្ឋមួយផ្សេងទៀត មិនតម្រូវថាត្រូវតែមានការបង្កើតទំនាក់ទំនងការទូត ឬសម្ព័ន្ធណាមួយរវាងរដ្ឋទាំងពីរនោះឡើយ។ ដូចគ្នាដែរ ការផ្តាច់ទំនាក់ទំនងរវាងរដ្ឋទាំងពីរ មិននាំទៅរកការដកការទទួលស្គាល់រដ្ឋឡើយ។

ការមិនទទួលស្គាល់រដ្ឋ ឬរដ្ឋាភិបាលមួយ មិនមែនមានន័យថា អង្គភាពនោះមិនអាចទទួលបានសិទ្ធិ និងការកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិទេ។ អ្វីដែលត្រូវកត់សម្គាល់គឺថា ក្នុងច្បាប់អន្តរជាតិ អត្ថិភាពនយោបាយនៃរដ្ឋមិនមែនពឹងផ្អែកលើការទទួលស្គាល់ពីរដ្ឋដទៃឡើយ ហេតុនេះរដ្ឋដែលមិនមានការទទួលស្គាល់ អាចនឹងចាត់ជាកម្មវត្ថុមួយនៃច្បាប់អន្តរជាតិផងដែរ។ រដ្ឋដែលមិនមានការទទួលស្គាល់ ត្រូវទទួលបានសិទ្ធិជាក់លាក់ និងមានកាតព្វកិច្ចជាច្រើនក្រោមច្បាប់អន្តរជាតិ។ អង្គភាពនេះ មានសិទ្ធិការពារបូរណភាព និងឯករាជ្យភាពរបស់ខ្លួន។ ការអនុវត្តសិទ្ធិទាំងនេះ ដោយរដ្ឋដែលមិនមានការទទួលស្គាល់ មិនមានកម្រិតណាមួយឡើយ ពោលគឺអាចអនុវត្តន៍ធម្មតាដូចគ្នានឹងរដ្ឋដែលមានការទទួលស្គាល់អញ្ចឹងដែរ។ ជាងនេះទៅទៀត រដ្ឋដែលមិនមានការទទួលស្គាល់ត្រូវស្ថិតក្រោមកាតព្វកិច្ចនានាជាច្រើន ជាពិសេសពាក់ព័ន្ធជាមួយនឹងច្បាប់សង្គ្រាម។

### ២.៣.២ វិបាកកម្រិតជាតិនៃការទទួលស្គាល់

ការទទួលស្គាល់រដ្ឋមួយ មានន័យថាជាការទទួលស្គាល់សិទ្ធិរបស់រដ្ឋនោះក្នុងការទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិនៅចំពោះមុខតុលាការជាតិ។ ដ្បិតតែថា ការទទួលស្គាល់គឺជាកិច្ចអនុវត្តដោយអង្គការនីតិប្រតិបត្តិរបស់រដ្ឋមួយក៏ពិតមែន ប៉ុន្តែវិបាកនៃការទទួលស្គាល់នោះក៏ត្រូវមានឥទ្ធិពលដល់ការអនុវត្តរបស់អង្គការតុលាការផងដែរ ព្រោះថាសកម្មភាពរបស់រដ្ឋាភិបាលលើឆាកអន្តរជាតិ ជាសកម្មភាពតំណាងឱ្យរដ្ឋទាំងមូល។ ក្រៅពីនេះ ការទទួលស្គាល់ក៏មានឥទ្ធិពាលសកម្មភាពមួយចំនួនរបស់អង្គការនីតិប្បញ្ញត្តិរបស់រដ្ឋផងដែរ។

# ជំពូកទី៣

# ករណីកោះតៃវ៉ាន់

# ជំពូកទី៣
# ករណីកោះតៃវ៉ាន់

## ៣.១ ស្ថានភាពជាក់ស្តែងៈ កោះតៃវ៉ាន់

ការប្រឈមមុខដាក់គ្នារវាងសហរដ្ឋអាមេរិក និងចិន លើបញ្ហាតៃវ៉ាន់ កើតឡើងដោយសារតែមានដំណើរទស្សនកិច្ចរបស់ប្រធានសភាតំណាងសហរដ្ឋអាមេរិក លោកស្រី ណាន់ស៊ី ផេឡូស៊ី (Nancy Pelosi) *ប្រធានសភាសហរដ្ឋអាមេរិក* នៅតៃវ៉ាន់ នៅយប់ថ្ងៃទី២ ខែសីហា ឆ្នាំ២០២២។ នេះជាទស្សនកិច្ចរបស់មន្ត្រីសហរដ្ឋអាមេរិកមានឋានៈខ្ពស់មួយ ទៅតៃវ៉ាន់លើកដំបូងចាប់តាំងពីឆ្នាំ ១៩៩៧។ កាលឆ្នាំនោះ លោក Newt Gingrich ប្រធានសភាតំណាងសហរដ្ឋអាមេរិក ក៏បានធ្វើទស្សនកិច្ចនៅតៃវ៉ាន់ដែរ។

ស្របគ្នានេះ ក្រសួងការបរទេសចិន ក្នុងថ្ងៃទី២ ខែសីហា ឆ្នាំ២០២២ បានថ្កោលទោសយ៉ាងខ្លាំង ចំពោះដំណើរទស្សនកិច្ចរបស់ប្រធានសភាតំណាងនៅតៃវ៉ាន់។ បើតាមក្រសួងការបរទេស ក្រុងប៉េកាំង បានដាក់ពាក្យតវ៉ារួចហើយជាមួយក្រុងវ៉ាស៊ីនតោន។ ឆ្លើយតបសកម្មភាពអាមេរិក រដ្ឋាភិបាលចិន បានហៅផែនការនៃដំណើរទស្សនកិច្ចរបស់លោកស្រី ផេឡូស៊ី ទៅកោះតៃវ៉ាន់ថាជា **ទង្វើបង្កហេតុ**។ ប្រធានាធិបតីចិន លោកស៊ី ជិនភីង បានប្រាប់សមភាគីអាមេរិក លោក ចូ បៃឌិន ដោយផ្ទាល់ថា ប្រទេសណាលេងជាមួយភ្លើង ប្រទេសនោះនឹងរលាក។[39]

**ក្រសួងការបរទេសកម្ពុជា ចេញសេចក្តីថ្លែងការណ៍ស្តីពីច្រកសមុទ្រតៃវ៉ាន់**មានដូចខាងក្រោម[40] ៖

**រាជរដ្ឋាភិបាលកម្ពុជា បានអះអាងថា ខ្លួនបាននិងកំពុង តាមដានយ៉ាងយកចិត្តទុកដាក់ សភាពការណ៍វិវត្តន៍ថ្មីៗ នៅច្រក សមុទ្រតៃវ៉ាន់ និងសូម ធ្វើសេចក្តីថ្លែងការណ៍ ដូចខាងក្រោមៈ**

រាជរដ្ឋាភិបាលកម្ពុជា សូមសម្តែងនូវការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះការកើនឡើង នូវភាពតានតឹង ថ្មីៗនៅច្រកសមុទ្រតៃវ៉ាន់ និងស្នើសុំឱ្យគ្រប់ ភាគីពាក់ព័ន្ធ គោរពចំពោះ កិច្ចព្រមព្រៀងទាំងឡាយ ដែលត្រូវបានចុះហត្ថលេខារវាង សាធារណរដ្ឋប្រជាមានិតចិន និងសហរដ្ឋអាមេរិក ដូចដែលមានចែងក្នុងសេចក្តី ថ្លែងការណ៍រួមនានាកន្លងមក រវាង ភាគីទាំងពីរ។

រាជរដ្ឋាភិបាលកម្ពុជា ប្រកាន់ខ្ជាប់ជានិច្ចនូវ «គោលនយោបាយ ចិនតែមួយ» ដោយឥតងាករេ ហើយចាត់ ទុកបញ្ហានានាពាក់ព័ន្ធ នឹងហុងកុង តៃវ៉ាន់ ទីបេ និងស៊ីនជាំង ជាកិច្ចការ ផ្ទៃក្នុងរបស់ ចិន និង ជាសិទ្ធិ អធិបតេយ្យ របស់សាធារណរដ្ឋប្រជាមានិតចិន។

[39] គេហទំព័រៈ https://thmeythmey.com/?page=detail&id=117820 ចូលមើលចុងក្រោយ នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៣។
[40] គេហទំព័រៈ http://www.freshnewsasia.com.html ចូលមើលចុងក្រោយ នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៣។

រាជរដ្ឋាភិបាលកម្ពុជា បានអំពាវនាវ ឱ្យភាគីពាក់ព័ន្ធទាំងអស់ ស្វះស្វែង រកដំណោះស្រាយប្រកប ដោយសន្តិវិធី រក្សាស្ថានភាពដើម និងចៀសវាង ការបង្កហេតុ ដើម្បីបុព្វហេតុ នៃ សន្តិភាព ស្ថិរភាព វឌ្ឍនភាព និងវិបុលភាពនៅក្នុងតំបន់ និងពិភពលោក។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ចិនបានសម្លឹងដោយភាពខឹងសម្បារចំពោះការរំកិលជិតគ្នារវាងសហរដ្ឋអាមេរិក និងតៃវ៉ាន់ នោះ បើទោះបីជាក្រុងវ៉ាស៊ីនតោន និងក្រុងតៃប៉ិក គ្មានទំនាក់ទំនងការទូតផ្លូវការវាងគ្នាក៏ដោយ។ អាមេរិកជាដៃគូដ៏សំខាន់បំផុតរបស់តៃវ៉ាន់ និងជាអ្នកផ្គត់ផ្គង់អាវុធឱ្យតៃវ៉ាន់។ គួរបញ្ជាក់ថា ចិនតែងចាត់ទុកតៃវ៉ាន់ជាខេត្តមួយរបស់ខ្លួន។ ក្នុងរយៈពេលនៃការកាន់តំណែងប្រធានាធិបតីចិនរបស់លោក ស៊ី ជីនពីងជាង ១០ឆ្នាំកន្លងទៅ ទំនាក់ទំនងរវាងចិន និងតៃវ៉ាន់ដែលបានធ្លាក់ទាបខ្លាំងបានស្គាល់ភាពយ៉ាប់យ៉ឺនថែមទៀតនាប៉ុន្មានឆ្នាំកន្លងទៅ។

### ៣.១.១ បញ្ហាប្រជាពលរដ្ឋ

ជាការពិត កោះតៃវ៉ាន់ ពិតជាមានសញ្ជាតិតៃវ៉ាន់ ហើយមានប្រជាជនដែលប្រើប្រាស់លិខិតឆ្លងដែនរបស់តៃវ៉ាន់ដូចដែលបានលើកឡើងនៅក្នុងជំពូកទី១ រួចរាល់មកហើយ។ ជាការបញ្ជាក់កាន់តែច្បាស់អំពីលិខិតឆ្លងដែនសូមលើកយកនូវការប្រកាសព័ត៌មានរបស់ក្រសួងការបរទេសតៃវ៉ាន់ លេខ ២៨៣ ដែលបានប្រកាសព័ត៌មានអំពីលិខិតឆ្លងដែនរបស់ខ្លួន នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។[41] ក្នុងសេចក្តីប្រកាសនេះបានបញ្ជាក់ច្បាស់អំពីការប្រើប្រាស់លិខិតឆ្លងដែលរបស់ខ្លួន ជាពិសេសកំណត់អត្តសញ្ញាណរបស់ខ្លួន ជាងនេះទៅទៀត ក្រសួងការបរទេសតៃវ៉ាន់ បានបញ្ជាក់អំពីទម្រង់នៃការដាក់ថែមអក្សរអង់គ្លេសជាផ្លូវការ «REPUBLIC OF CHINA» និងពង្រីកទំហំពុម្ពអក្សរ «TAIWAN» នេះជាការបញ្ជាក់យ៉ាងច្បាស់អំពីអត្តសញ្ញាណលិខិតឆ្លងដែននិងឆ្លុះបញ្ជាក់អំពីប្រជាជនពិតប្រាកដនៃជនជាតិតៃវ៉ាន់។

### ៣.១.២ បញ្ហារដ្ឋាភិបាល និង ទឹកដី

ក្នុងទ្រឹស្តីរដ្ឋាភិបាល រដ្ឋចាំបាច់ត្រូវមានគោលនយោបាយរបស់ខ្លួន ស្ថាប័នដឹកនាំរបស់ខ្លួនដូចការណ៍ជាក់ស្តែង។ តែទោះជាយ៉ាងណាបញ្ហារដ្ឋាភិបាលនេះមានភាពស្មុគស្មាញមិនត្រឹមតែកោះតៃវ៉ាន់តែបណ្តាប្រទេសផ្សេងៗក៏ដូចគ្នា។ កត្តាស្មុគស្មាញនេះសូមលើកយកបញ្ហាស្ថានភាពនៃកោះតៃវ៉ាន់និងប្រទេសចិនមកសិក្សា ក៏ដូចជាបង្ហាញឱ្យឃើញពីភាពស្មុគស្មាញ។

[41] គេហទំព័រ៖ https://www.boca.gov.tw/cp-220-6110-a3137-2.html ចូលមើលចុងក្រោយ នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៣។

ប្រភពប្រវត្តិសាស្ត្របានបង្ហាញថា កោះតៃវ៉ាន់បានចូលមកក្រោមការគ្រប់គ្រងរបស់ចិនជាលើកដំបូងក្នុងសតវត្សទី១៧ នៅក្នុងរាជវង្សឈីង (Qing Emperor)។ ក្រោយមកទៀតនៅឆ្នាំ១៨៩៥ កោះតៃវ៉ាន់នេះត្រូវបានប្រគល់ទៅឱ្យប្រទេសជប៉ុនបន្ទាប់ពីចាញ់សង្គ្រាមចិនជប៉ុនលើកដំបូង។[42]

នៅឆ្នាំ១៩៤៥ បន្ទាប់ពីជប៉ុនចាញ់សង្គ្រាមលោកលើកទី២ ក៏បានប្រគល់កោះនេះមកឱ្យប្រទេសចិនវិញ។ ដ្បិតថាយ៉ាងនេះក្តីប្រទេសចិនឬហៅថាចិនដីគោកបានផ្ទុះនៅសង្គ្រាមស៊ីវិលរវាងកងកម្លាំងរដ្ឋាភិបាលជាតិនិយមដែលដឹកនាំដោយលោក Chiang Kai-shek និងបក្សកុម្មុយនិស្តរបស់ ម៉ៅ សេទុង។

ពួកកុម្មុយនិស្តបានឈ្នះនៅឆ្នាំ១៩៤៩ ហើយបានកាន់កាប់នៅទីក្រុងប៉េកាំង។

ឈៀង កៃឆេក និងអ្វីដែលនៅសេសសល់ពីគណបក្សជាតិនិយម ដែលត្រូវបានគេស្គាល់ថាជា គួ មីនតាង បានភៀសខ្លួនទៅកាន់កោះតៃវ៉ាន់ ជាកន្លែងដែលពួកគេគ្រប់គ្រងអស់រយៈពេលជាច្រើនទសវត្សរ៍បន្ទាប់។

ចិនចង្អុលទៅប្រវត្តិសាស្ត្រនេះ ដើម្បីនិយាយថា តៃវ៉ាន់ជាខេត្តរបស់ចិនដើមឡើយ។ ប៉ុន្តែជនជាតិតៃវ៉ាន់បានចង្អុលទៅប្រវត្តិសាស្ត្រដូចគ្នាដើម្បីប្រកែកថាពួកគេមិនដែលជាផ្នែកមួយនៃរដ្ឋចិនសម័យទំនើបដែលត្រូវបានបង្កើតឡើងដំបូងបន្ទាប់ពីបដិវត្តន៍នៅឆ្នាំ១៩១១ ឬសាធារណរដ្ឋប្រជាមានិតចិនដែលត្រូវបានបង្កើតឡើងក្រោមលោក ម៉ៅ សេទុង នៅឆ្នាំ១៩៤៩។

សូមគូសបញ្ជាក់ផងដែរថាទោះបីជាមានការគូសបញ្ជាក់ពីប្រវត្តិសាស្ត្រដែលជនជាតិតៃវ៉ាន់ប្រកែកថាមិនមែនជាផ្នែកមួយនៃរដ្ឋចិនក៏ពិតមែនតែប្រវត្តិសាស្ត្រចិនក៏មិនអាចប្រកែកបានដោយហេតុថាដែនកោះនេះត្រូវបានជប៉ុនប្រគល់ឱ្យចិនដោយចាញ់សង្គ្រាម ហើយជាការគ្រប់គ្រងក្រោមប្រទេសចិនបើទោះបីស្ថានភាពនយោបាយចិននិងកោះតៃវ៉ាន់យ៉ាងណាក្តី។ ជាការគូសបញ្ជាក់មួយទៀតបើទោះបីរដ្ឋាភិបាលណាមួយមានការផ្លាស់ប្តូរទីតាំងក្តី ជាក់ស្តែងដូចជា គួ មីងតាំង បានភៀសខ្លួនទៅកាន់កោះតៃវ៉ាន់ តែកោះតៃវ៉ាន់នេះពុំមានអនុសញ្ញា ឬសន្ធិសញ្ញា ឬច្បាប់អន្តរជាតិទាំងឡាយណាមកទទួលស្គាល់ពីការបំបែកខ្លួនចេញពីដែនដីអធិបតេយ្យរបស់ចិននោះទេ។

ចំពោះបញ្ហារដ្ឋាភិបាលវិញ ក្រោយពីគណបក្សកុម្មុយនីស្តចិនដឹកនាំដោយលោក ម៉ៅ សេទុង ក្នុងឆ្នាំ១៩៤៩ របបសាធារណរដ្ឋចិន ដឹកនាំដោយលោក ជាង កៃជៀក បានភៀសខ្លួនទៅបង្កើតរដ្ឋាភិបាលមួយនៅកោះតៃវ៉ាន់ ក្នុងកំឡុងពេលខ្លួនមានឋានៈជារដ្ឋស្របច្បាប់ដែលមានអាសនៈនៅក្នុងអង្គការសហប្រជាជាតិ។ ប៉ុន្តែនៅខែតុលា ឆ្នាំ១៩៧១ ផ្អែកតាមដំណោះស្រាយលេខ ២៧៥៨[43] អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិបាន

[42] គេហទំព័រ៖ https://www.taiwan.gov.tw/content_3.php ចូលមើលចុងក្រោយ នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៣។

[43] គេហទំព័រ៖ https://digitallibrary.un.org/record/192054?ln=en ចូលមើលចុងក្រោយ ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៣។

ដកអាសនៈពីរបបសាធារណរដ្ឋចិន (កោះតៃវ៉ាន់បច្ចុប្បន្ន) មកឱ្យរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន ហៅថា ចិនដីគោក វិញ ដែលមានខ្លឹមសារដូចខាងក្រោម៖

២៧៥៨ (XXVI). ការស្តារឡើងវិញនូវសិទ្ធិស្របច្បាប់នៃសាធារណរដ្ឋប្រជាមានិតចិននៅក្នុងអង្គការសហប្រជាជាតិមហាសន្និបាត,រំលឹកឡើងវិញនូវគោលការណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិ។

ដោយចាត់ទុកថា ការស្តារឡើងវិញនូវសិទ្ធិស្របច្បាប់នៃសាធារណរដ្ឋប្រជាមានិតចិនគឺចាំបាច់ទាំងការការពារធម្មនុញ្ញអង្គការសហប្រជាជាតិ និងសម្រាប់បុព្វហេតុដែលអង្គការសហប្រជាជាតិត្រូវបម្រើក្រោមធម្មនុញ្ញ។

ដោយទទួលស្គាល់ថា តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនគឺជាតំណាងស្របច្បាប់តែមួយគត់របស់ប្រទេសចិនទៅកាន់អង្គការសហប្រជាជាតិ ហើយថាសាធារណរដ្ឋប្រជាមានិតចិនគឺជាសមាជិកអចិន្ត្រៃយ៍មួយក្នុងចំណោមសមាជិកអចិន្ត្រៃយ៍ទាំងប្រាំនៃក្រុមប្រឹក្សាសន្តិសុខ។

សម្រេចចិត្តស្តារសិទ្ធិទាំងអស់របស់ខ្លួនឡើងវិញចំពោះសាធារណជនរបស់ប្រជាជនចិន និងទទួលស្គាល់តំណាងរដ្ឋាភិបាលរបស់ខ្លួនថាជាតំណាងស្របច្បាប់តែមួយគត់របស់ប្រទេសចិនទៅកាន់អង្គការសហប្រជាជាតិ និងដើម្បីបណ្តេញតំណាងរបស់ Chang Kai-shek ចេញពីកន្លែងនោះ។ ពួកគេកាន់កាប់ដោយខុសច្បាប់នៅអង្គការសហប្រជាជាតិ និងនៅក្នុងអង្គការទាំងអស់ដែលទាក់ទងនឹងវា។

រាប់ចាប់តាំងពីពេលនោះមក សហគមន៍អន្តរជាតិ បានទទួលស្គាល់ជាទូទៅពីគោលការណ៍ចិនតែមួយ ពោលគឺលើពិភពលោកនេះគឺមានចិនតែមួយគត់ ចំពោះតៃវ៉ាន់គ្រាន់តែជាដែនកោះមួយរបស់ប្រទេសចិនប៉ុណ្ណោះ។ ជាពិសេសទៅទៀត តៃវ៉ាន់ក៏គ្មានអាសនៈក្នុងអង្គការសហប្រជាជាតិនោះទេដែលមានន័យថា តៃវ៉ាន់មិនមែនជារដ្ឋអធិបតេយ្យ ហើយរដ្ឋាភិបាល សាធារណរដ្ឋប្រជាមានិតចិន គឺតំណាងឱ្យប្រទេសចិនទាំងមូលក្នុងនោះបូករួមទាំងតំបន់តៃវ៉ាន់ផងដែរ។

## ៣.២ ការសិក្សាវិភាគ ចំណុចវិជ្ជមាន និងចំណុចអវិជ្ជមាន

បន្ទាប់ពីបានលើកឡើងជាច្រើនអំពីទ្រឹស្តីដែលទាក់ទងនឹងការទទួលស្គាល់រដ្ឋ ជាពិសេសសញ្ញាណនិងធាតុផ្សំទាំង៣រួចមក នៅក្នុងជំពូកទី៣នេះនឹងវិលត្រឡប់ថយក្រោយ ដើម្បីពិនិត្យពីស្ថានភាពជាក់ស្តែងកើតមានជាបញ្ហាក្នុងកោះតៃវ៉ាន់ និងការវិភាគអំពីចំណុចវិជ្ជមាន និងអវិជ្ជមាន ក៏ដូចជាបញ្ហានានាជាច្រើនទៀតផងដែរ។

### ៣.២.១ ចំណុចវិជ្ជមាន

តាមរយការសិក្សាជាច្រើន ទោះស្ថិតក្នុងស្ថានភាពទ្រឹស្តី សញ្ញាណ ធាតុផ្សំ សបញ្ជាក់ឱ្យឃើញគុណសម្បត្តិជាច្រើនដែលបញ្ជាក់ថាកោះតៃវ៉ាន់ពិតជាគ្រប់គ្រាន់ក្នុងភាពជារដ្ឋទោះបីមានស្ថានភាពស្មុគស្មាញយ៉ាងណាក្តី មិនថាទឹកដី ប្រជាពលរដ្ឋ ឬរដ្ឋាភិបាលក្តី តៃវ៉ាន់សុទ្ធតែមានគ្រប់គ្រាន់មិនអាចខ្វះបាន។

លើសពីនេះ រដ្ឋាភិបាលកោះតៃវ៉ាន់ក៏មានទំនាក់ទំនងល្អជាមួយសហរដ្ឋអាមេរិក និងប្រទេសខ្លះទៀតដែលក្នុងស្ថានភាពដ៏លំបាកពិសេសការគម្រាមកំហែងអំពីចិន តែងមានការឃ្លាំមើល ការជួយពីសំណាក់សហរដ្ឋអាមេរិក។ ដូចជាករណីនៅដើមឆ្នាំ២០២៣ សហរដ្ឋអាមេរិកបានឃ្លាំងមើល ចំពោះការធ្វើសមយុទ្ធយោធារបស់ចិននៅជុំវិញតៃវ៉ាន់ ដែលសមយុទ្ធយោធាធ្វើឡើងក្នុងរយៈពេល៣ថ្ងៃ ក្រោយពីថ្នាក់ដឹកនាំតៃវ៉ាន់ទើបត្រឡប់មកពីសហរដ្ឋអាមេរិក ចំនួន១ថ្ងៃ។[44] ការការពាររបស់សហរដ្ឋអាមេរិក ពុំមែនត្រឹមតែកើតឡើងនៅឆ្នាំ២០២៣ នេះ ប៉ុណ្ណោះនោះទេ សូមត្រឡប់ក្រោយដែលនៅឆ្នាំ២០២២ ប្រធានសភាអាមេរិកលោកស្រី Nancy Pelosi បានប្តេជ្ញាថា សហរដ្ឋអាមេរិកនឹងមិនឱ្យកោះតៃវ៉ាន់នៅឯកោឡើយ ខណៈដែលទីក្រុងប៉េកាំងបានបង្កើនសមយុទ្ធយោធា និងការលុកលុយដោយយន្តហោះចម្បាំង បន្ទាប់ពីលោកស្រីបានបំពេញទស្សនកិច្ចទៅកាន់កោះនេះ។ យោងតាមសារព័ត៌មាន CNN ចេញផ្សាយនៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២ បានឱ្យដឹងថា ថ្លែងនៅក្នុងសន្និសីទសារព័ត៌មានក្នុងទីក្រុងតូក្យូ ប្រទេសជប៉ុន អំឡុងពេលនៃដំណើរទស្សនកិច្ចនៅតំបន់អាស៊ីរបស់លោកស្រី, លោកស្រី Pelosi បាននិយាយថា ប្រទេសចិនបានស្វែងរកការផ្តាច់តៃវ៉ាន់ចេញពីសហគមន៍អន្តរជាតិ ប៉ុន្តែចិននឹងមិនអាចរារាំងមន្ត្រីសហរដ្ឋអាមេរិកពីការធ្វើដំណើរនៅទីនោះទេ (កោះតៃវ៉ាន់)។[45]

### ៣.២.២ ចំណុចអវិជ្ជមាន

ដ្បិតកោះតៃវ៉ាន់មានភាពគ្រប់គ្រាន់ដែលជាគុណសម្បត្តិឬជាចំណុចវិជ្ជមានក្តី តែមានបញ្ហាជាច្រើនស្ថិតក្នុងចំណុចអវិជ្ជមានរារាំងកោះតៃវ៉ាន់ក្នុងការទទួលស្គាល់រដ្ឋក្នុងនីតិអន្តរជាតិ។

#### ៣.២.២.១ សមត្ថភាពក្នុងការកសាងទំនាក់ទំនងជាមួយរដ្ឋដទៃ

ពាក្យថា អធិបតេយ្យរដ្ឋ គឺជាគោលការណ៍របស់រដ្ឋមួយដែលមិនមានការស្ថិតនៅក្រោមអាជ្ញាធរថ្នាក់លើណាមួយឡើយ ពោលគឺជាអំណាចផុតលេខរបស់រដ្ឋមួយ ក្នុងការអនុវត្តអំណាចរបស់ខ្លួន រួមមានអំណាចនីតិ

---

[44] គេហទំព័រ៖ https://m.freshnewsasia.com/index.php/en/internationalnews/285957-2023-04-09-02-53-57.html ចូលមើលចុងក្រោយ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣។

[45] គេហទំព័រ៖ https://dap-news.com/international/2022/08/05/268438/ ចូលមើលចុងក្រោយ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣។

ប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ដែលជាអំណាចធំរបស់រដ្ឋមួយ។ ការសម្គាល់នូវអធិបតេយ្យរបស់រដ្ឋមួយបាន ពោលគឺគេពិនិត្យលើភាពឯករាជ្យជាតិរបស់រដ្ឋនោះផងដែរ។

បើទោះបីជាគោលការណ៍ទាំងអស់នេះពេញលេញយ៉ាងណាក៏ដោយ ភាពឯករាជ្យនៃប្រទេសមួយឬរដ្ឋមួយដែលមានអធិបតេយ្យពេញលេញ គឺមិនត្រូវបានបាត់បង់នោះឡើយ។ ឯករាជ្យ ដែលលើកយកមកនិយាយនេះគឺសំដៅលើអំណាចដែលមិនស្ថិតក្រោមបញ្ជារបស់គេ តែមិនមែនមានន័យថា មិនអាស្រ័យជាមួយគេនោះទេ ព្រោះថារដ្ឋទាំងអស់ត្រូវតែមានការប្រាស្រ័យទាក់ទងជាមួយគ្នាទៅវិញទៅមក។ រដ្ឋមួយមានឯករាជ្យ នោះទើបមានអធិបតេយ្យពេញ។

ចំពោះបញ្ហាអធិបតេយ្យ និងឯករាជ្យរបស់កោះតៃវ៉ាន់ បើពិនិត្យមួយភ្លែកទៅហាក់បីដូចជាពេញលេញ តែបើពិនិត្យនិងសិក្សាឱ្យស៊ីជម្រៅហាក់ដូចជាខ្វះនូវឯករាជ្យភាព ពិសេសពុំស្របនឹងចំណុចទី៣នោះឡើយដែលថាជាកត្តាសមត្ថកិច្ចក្នុងការកសាងទំនាក់ទំនងជាមួយរដ្ឋដទៃ។ ការកំណត់ថាកោះតៃវ៉ាន់ពុំមានឯករាជ្យភាព ឬពុំមានជាសមត្ថកិច្ចនៃការកសាងទំនាក់ទំនងរដ្ឋដទៃនោះ យើងពុំអាចកំណត់ដោយការនិយាយដោយម៉ាត់ទទេ ឬជាបញ្ហាផ្សេងៗនោះទេ។ ដ្បិតថាវាជារឿងភូមិសាស្ត្រនយោបាយ ផលប្រយោជន៍ ឬជាទំនាក់ទំនងបែបអន្តរជាតិក៏ពិតមែន តែកត្តាទំនាក់ទំនងអន្តរជាតិនោះត្រូវកំណត់ទៅក្នុងចំណុចនេះ និងក៏ជាកត្តាដែលត្រូវសិក្សាអំពីច្បាប់អន្តរជាតិដូចគ្នា។

### ៣.២.២.២ ករណីនៃការទទួលស្គាល់សាធារណរដ្ឋប្រជាមានិតចិន

ករណីដែលសាធារណរដ្ឋប្រជាមានិតចិន សុំចូលជាសមាជិករបស់អង្គការសហប្រជាជាតិនៅក្នុងកំឡុងឆ្នាំ១៩៥០ នៅពេលដែលសាធារណរដ្ឋប្រជាមានិតចិនមិនទាន់បានការទទួលស្គាល់ពីសំណាក់សហរដ្ឋអាមេរិក ពីព្រោះសហរដ្ឋអាមេរិកទទួលស្គាល់ចិនតៃវ៉ាន់ នៅក្នុងទំនាក់ទំនងខាងការទូត។ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ Trygve Lie[46] នៅក្នុងអនុស្សរណៈមួយ ផ្ញើទៅកាន់ប្រធានក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៥០ បានកត់សំគាល់ថា សមាជិករបស់អង្គការសហប្រជាជាតិនឹងបោះឆ្នោតដោយត្រឹមត្រូវដើម្បីទទួលយកនូវតំណាងនៃរដ្ឋមួយដែលមិនបានទទួលស្គាល់ ឬមិនមានទំនាក់ទំនងការទូតអ្វីទាំងអស់ហើយការឆ្នោតសម្រេចរបៀបនេះមិនផ្សារភ្ជាប់ទៅនឹងការទទួលស្គាល់ ឬនៅលើទំនាក់ទំនងការទូតដែលបានរួចទៅហើយដែរ។ មកដល់ឆ្នាំ១៩៥០ ក្រសួងការបរទេសសហរដ្ឋអាមេរិកបានកំណត់គោលនយោបាយរបស់សហរដ្ឋអាមេរិក ដើម្បីទទួលស្គាល់រដ្ឋ និងរដ្ឋាភិបាលមួយទៅតាមនីតិវិធីដូចតទៅ៖[47]

---

[46] លោក Trygve Lie ជាអគ្គលេខាធិការអង្គការសហប្រជាជាតិលើកទីមួយ ដែលបានចូលកាន់តំណែង ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៤៦ ដល់ថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៥៣។

[47] ខៀវ ថវិកា, *នីតិអន្តរជាតិសាធារណៈ* Public International Law *ភាគទី១* (ឆ្នាំ២០១០)

ទី១ ការសម្រេចថា ដើម្បីនឹងទទួលស្គាល់របបថ្មីមួយក្នុងឋានៈជារដ្ឋាភិបាលរបស់ប្រទេសមួយ គឺត្រូវធ្វើឡើងដោយគិតទៅដល់ផលប្រយោជន៍ជាតិដ៏ពិសេសរបស់សហរដ្ឋអាមេរិក។ រាល់កាលៈទេសៈនីមួយៗនៃការទទួលស្គាល់ ឬមិនទទួលស្គាល់ គឺអាស្រ័យបិតនៅលើកត្តាជាក់ស្តែង និងកត្តានយោបាយនានា។ នៅក្នុងច្បាប់របស់ព្រឹទ្ធសភា (the Senate Act) នាខែកញ្ញា ឆ្នាំ១៩៦៩ ការទទួលស្គាល់ពីសំណាក់សហរដ្ឋអាមេរិក ចំពោះរដ្ឋណាមួយត្រូវតែគិតគូរទៅដល់ផលប្រយោជន៍របស់ជាតិ។

ទី២ ជាទម្លាប់ សហរដ្ឋអាមេរិកមានចរិតលក្ខណវិនិច្ឆ័យ ៣យ៉ាង សម្រាប់ការទទួលស្គាល់ ឬប្រឆាំងនឹងការទទួលស្គាល់រដ្ឋាភិបាលណាមួយ៖[48]

ក.វិសាលភាពនៃប្រសិទ្ធភាពចំពោះការគ្រប់គ្រងទឹកដី និងការគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋមួយ

ខ. វិសាលភាពនៃការទទួលយកជាសាធារណៈនៅក្នុងការគ្រប់គ្រងអំណាច

គ. រដ្ឋាភិបាលនោះយកចិត្តទុកដាក់គោរពនូវកាតព្វកិច្ចអន្តរជាតិដោយពេញលេញ និងជំហររបស់រដ្ឋាភិបាលនោះសំដៅឆ្ពោះមកសហរដ្ឋអាមេរិក។

ទី៣ ចាប់តាំងពីឆ្នាំ១៩៦៥មក សហរដ្ឋអាមេរិកបានខិតខំជៀសវាងធ្វើសេចក្តីប្រកាស ទទួលស្គាល់រដ្ឋាភិបាលណាដែលកើតចេញមកពីរដ្ឋប្រហារ ឬពីការបដិវត្តផ្លាស់ប្តូរសង្គមផ្សេងៗ។

### ៣.២.២.៣ ភាពអវិជ្ជមានដ៏ធំបំផុតនៃស្ថានភាពនយោបាយ

ស្ថានភាពនយោបាយរបស់កោះតៃវ៉ាន់គឺនូវមានវិវាទច្រើន។ សាធារណរដ្ឋចិនបានបាត់បង់ឈ្មោះជារដ្ឋតំណាងប្រទេសចិននៅអង្គការសហប្រជាជាតិក្នុងឆ្នាំ១៩៧១ បន្ទាប់ពីប្រជាជាតិលើពិភពលោកភាគច្រើនបានបោះឆ្នោតទទួលស្គាល់សាធារណរដ្ឋប្រជាមានិតចិន។ ចាប់តាំងពីពេលនោះមក សាធារណរដ្ឋចិនតែងតែអះអាងខ្លួនថាជារដ្ឋាភិបាលស្របច្បាប់នៃប្រជាជាតិចិនទាំងមូល។ ចំណែកឯសាធារណរដ្ឋប្រជាមានិតចិនវិញបានអះអាងថាកោះតៃវ៉ាន់គឺជាទឹកដីរបស់ខ្លួនហើយនឹងមិនព្រមបង្កើតទំនាក់ទំនងការទូតជាមួយរដ្ឋប្រទេសណាដែលទទួលស្គាល់តៃវ៉ាន់ឡើយ។ តៃវ៉ាន់បានរក្សាទំនាក់ទំនងការទូតផ្លូវការជាមួយរដ្ឋចំនួន ១៥ នៅក្នុងចំណោមរដ្ឋជាសមាជិកអង្គការសហប្រជាជាតិសរុបចំនួន ១៩៣ ខណៈដែលប្រទេសជាច្រើនផ្សេងៗទៀតបានរក្សាទំនាក់ទំនងការទូតក្រៅផ្លូវការជាមួយតៃវ៉ាន់តាមរយៈការិយាល័យតំណាងនិងស្ថាប័នដែលដើរតួនាទីជាស្ថានទូតនិងស្ថានកុងស៊ុល។ នៅក្នុងអង្គការអន្តរជាតិដែលមានសាធារណរដ្ឋប្រជាមានិតចិន ជាសមាជិក តៃវ៉ាន់ត្រូវបានគេបដិសេធសមាជិកភាពជារឿយៗ ឬអនុញ្ញាតឱ្យខ្លួនចូលរួមតែក្នុងលក្ខខណ្ឌមិនមែនរដ្ឋក្រោមឈ្មោះផ្សេងៗ។

[48] ខៀវ ថវិកា, *នីតិអន្តរជាតិសាធារណៈ* Public International Law *ភាគទី១* (ឆ្នាំ២០១០)

តាមការសិក្សាស្រាវជ្រាវផងដែរក៏មានការលើកឡើងដោយការស្រាវជ្រាវរបស់ Blog ipleaders បានសរសេរថា៖

ប្រទេសចំនួន ១៥ បានទទួលស្គាល់តៃវ៉ាន់ថាជារដ្ឋមួយនៅទូទាំងពិភពលោក។ តៃវ៉ាន់ ត្រូវបានគេស្គាល់ជាផ្លូវការថាជាសាធារណរដ្ឋចិន និងត្រូវបានទទួលស្គាល់ដោយរដ្ឋជាសមាជិក19 នៃអង្គការសហប្រជាជាតិ។ ប្រទេសផ្សេងទៀតមានទំនាក់ទំនងអាជីវកម្មជាមួយតៃវ៉ាន់ ប៉ុន្តែពួកគេមិនទទួលល់វាថាជារដ្ឋមួយទេ។ តៃវ៉ាន់រក្សាទំនាក់ទំនងការទូតដោយគ្មានប្រសិទ្ធិភាពជាមួយសមាជិកអង្គ ការសហប្រជាជាតិចំនួន 57 នាក់ ផ្សេងទៀត។

ក្នុងកំឡុងពេលថ្មីៗនេះ ក្នុងចំណោមប្រទេសចំនួន១៥ ដែលបានទទួលស្គាល់តៃវ៉ាន់ថាជារដ្ឋ ត្រូវបានប្រទេសចំនួន២ទៀត ពោលគឺប្រទេសនីការ៉ាហ្គា នៅឆ្នាំ២០២១[49] និងប្រទេសហុងឌូរ៉ាស នៅឆ្នាំ២០២៣[50] បានផ្តាច់ទំនាក់ទំនងជាផ្លូវការជាមួយកោះតៃវ៉ាន់នឹងងាកមករកគោលការណ៍ចិនតែមួយវិញ។ គិតត្រឹមឆ្នាំ២០២៣ នេះកោះតៃវ៉ាន់មានត្រឹមតែប្រទេសចំនួន១៣ប៉ុណ្ណោះដែលមានទំនាក់ទំនងការទូតជាផ្លូវការជាមួយខ្លួន។

[49] គេហទំព័រ៖ https://www.theaustralian.com.au/world/nicaragua-switches-diplomatic-recognition-from-taiwan-to-china/news-story/3da67f9355f300dd2952970e32360a57 ចូលមើលចុងក្រោយ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣។

[50] គេហទំព័រ៖ https://edition.cnn.com/2023/03/14/asia/honduras-diplomatic-relations-china-taiwan-intl-hnk/index.html ចូលមើលចុងក្រោយ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣។

# សេចក្ដីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាលើប្រធានបទ «ការទទួលស្គាល់រដ្ឋ៖ ករណីកោះតៃវ៉ាន់» យើងសង្កេតឃើញថា ស្ថិតក្នុងការទទួលបានភាពជារដ្ឋចាំបាច់ណាស់ត្រូវគោរពលក្ខខណ្ឌជាច្រើន ពិសេសលក្ខខណ្ឌទាំង៣ ពោលគឺ កត្តាប្រជាជន កត្តាទឹកដី និងកត្តារដ្ឋាភិបាល ឱ្យបានពេញលេញ។ ដ្បិតមានប្រជាជនជាជាតិសាសន៍របស់ខ្លួនផ្ទាល់ក្ដី តែកត្តាទឹកដី ជាកត្តាចាំបាច់បំផុតដែលត្រូវស្ថិតនៅជាឯករាជ្យភាព ពុំមានការគ្រប់គ្រង ឬការបញ្ចូលដែនដីអធិបតេយ្យរបស់ខ្លួនស្ថិតក្នុងការគ្រប់គ្រងរបស់ប្រទេសណាមួយឡើយ។ លើសពីនេះទៅទៀត កត្តារដ្ឋាភិបាលផងនោះ ពុំមែនមានត្រឹមស្ថាប័នគ្រប់គ្រងតែប៉ុណ្ណោះនោះទេ ពោលគឺត្រូវមានការទំនាក់ទំនងការទូតជាមួយបណ្ដាប្រទេសផ្សេងៗជាច្រើនទៀតលើឆាកអន្តរជាតិ ពុំមែនត្រឹមតែមួយក្ដាប់តូច។

ចំពោះឆាកអន្តរជាតិផងដែរ ចាំបាច់ណាស់ក្នុងការចូលខ្លួនក្លាយជាសមាជិកនៃអង្គការនានា ពិសេសការទទួលស្គាល់ជាសកល ទោះក្នុងអង្គការអន្តរជាតិក្ដី ក្នុងអង្គការក្នុងតំបន់ក្ដី។

ដោយមើលឃើញនូវផលវិបាកទាំងនេះ ក៏ដូចជាភាពអវិជ្ជមានទាំងអស់នេះ ស្ថានភាពតៃវ៉ាន់នៅពុំទាន់អាចទៅរួចក្នុងការក្លាយខ្លួនទៅជាកោះឯករាជ្យពេញលេញ ឬភាពជារដ្ឋពេញលេញ។ ស្ថិតក្នុងស្ថានភាពបច្ចុប្បន្នស្របតាមគោលការណ៍ចិនតែមួយត្រូវបានទទួលស្គាល់ដោយប្រទេសជាច្រើន ស្របពេលការទូតជាមួយកោះតៃវ៉ាន់និងបណ្ដាប្រទេសផ្សេងៗមានលក្ខណៈបន្តិចបន្តួចនិងស្ថិតតែនៅក្នុងទំនាក់ទំនងជាលក្ខណៈសេដ្ឋកិច្ច ឬហៅមួយបែបទៀតថាជាផលប្រយោជន៍ប៉ុណ្ណោះ។ ដ្បិតសហរដ្ឋអាមេរិក ជារឿយៗ គេឃើញមានការជួយតាមបែបយោធាក្ដីជាមួយប្រទេសជាសម្ព័ន្ធមិត្តក្ដី គឺដើម្បីរារាំងមិនឱ្យចិនមានអំណាចកាន់តែខ្លាំងនៅក្នុងតំបន់ក៏ដូចជាពិភពលោកប៉ុណ្ណោះ។ តែមែនទែនទៅប្រទេសធំៗទាំងអស់ក្នុងពិភពលោកពុំមានការគាំទ្រឯណា ឬជាសកម្មភាពណាក្នុងការទទួលស្គាល់កោះតៃវ៉ាន់ជារដ្ឋឯករាជ្យនោះឡើយ។ ពិសេសក្នុងអង្គការសហប្រជាជាតិក៏ដូចគ្នា។

ចំពោះកត្តាជាតិនៃកោះតៃវ៉ាន់ឯណោះវិញ ក៏ពុំទាន់មានភាពម្ចាស់ការលើខ្លួនឯងក្នុងការប្រកាសឯករាជ្យដោយមើលឃើញអំពីជំហរមិនច្បាស់លាស់ របស់សហរដ្ឋអាមេរិក ដែលជាប្រហារអំណាចដ៏ធំមួយក្នុងពិភពលោក។ រីឯរដ្ឋធម្មនុញ្ញឯណោះវិញ តៃវ៉ាន់ពុំបានប្រកាសជាផ្លូវការនៅឡើងអំពីច្បាប់របស់ខ្លួន ប៉ុន្តែបែរជាមាននូវការបញ្ចូនដែនកោះនៃកោះតៃវ៉ាន់ទៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសចិន ស្របពេលពិភពលោកទទួលស្គាល់អំពីគោលការណ៍ចិនតែមួយផងដែរ។

# អនុសាសន៍

# អនុសាសន៍

ទន្ទឹមនឹងការលើកឡើងជាច្រើនអំពីកត្តាវិជ្ជមានរបស់កោះតៃវ៉ាន់ យើងក៏សង្កេតឃើញនូវភាពអវិជ្ជមានមួយចំនួនកើតចេញពីភាគីចិន ដែលតែងតែប្រើប្រាស់នូវកម្លាំងយោធា គម្រាមកំហែងដល់ដែនកោះតៃវ៉ាន់ ទោះពុំបង្កជាសង្គ្រាមក្តី តែជាការឆ្លុះបញ្ចាំងអំពីការប៉ុនប៉ងឈ្លានពាន ដែលធ្វើឱ្យពិភពលោកពុំមានការពេញចិត្ត និងទទូចជារឿយៗឱ្យមានការសម្របសម្រួលគ្នា។

ចំពោះភាគីសហរដ្ឋអាមេរិកឯណោះវិញក៏ពុំត្រូវប្រើកម្លាំងយោធា ឬការញុះញង់ឱ្យមានការបែកបាក់តាមរយៈពាក្យសំដីក្តី ឬសកម្មផ្សេងៗដែលប្រឆាំងនឹងចិននោះឡើយស្របពេលដែលខ្លួនកំពង់តែឯកភាពលើគោលការណ៍ចិនតែមួយ។ សហរដ្ឋអាមេរិកចាំបាច់ត្រូវតែដើរតួរជាដៃគូរសម្របសម្រួលចំពោះមុខស្ថានការណ៍ប្រសើរជាងការធ្វើនយោបាយផ្សេងៗនាំឱ្យមានការភ័នច្រឡំកើតមានឡើងរហូតបង្កទៅជាសង្គ្រាម។ លើសពីការសម្របសម្រួលសហរដ្ឋអាមេរិកត្រូវតែគិតគូរអំពីបញ្ហាប្រឈម ជាងការគិតគូរអំពីផលប្រយោជន៍ខ្លួនតែមួយហើយធ្វើឱ្យប៉ះពាល់ដល់សម្ព័ន្ធមិត្ត និងដៃគូរផ្សេងៗ ជាពិសេសបញ្ហាទាំងឡាយអាចបង្កទៅជាសង្គ្រាមចំពោះពិភពលោក។

ជារួមមក ទោះបីស្ថិតក្នុងស្ថានភាពណាក្តី ភាគីចិនគួរគប្បីមានការដោះស្រាយដោយសន្តិវិធី ឬដោយការទំនាក់ទំនងការទូត និងយកច្បាប់ជាតិក្តី ឬច្បាប់អន្តរជាតិ ជាគោល ពោលគឺបញ្ចៀសនូវសង្គ្រាមផង និងបញ្ជាក់នូវការយកច្បាប់ជាតិ និងអន្តរជាតិ ជាគោលផង។ ពុំនោះទេ សង្គ្រាមមួយអាច បង្កើតទៅជាសង្គ្រាមពីរ ឬបី ឬច្រើនបន្តបន្ទាប់ ហើយបោះបង់នូវច្បាប់អន្តរជាតិ បង្កឱ្យពិភពលោកប្រែក្លាយទៅជាគ្មានសណ្តាប់ធ្នាប់។ ស្របគ្នានោះផងដែរ គ្រប់ភាគីទាំងអស់គួរគប្បីគោរពនូវអ្វីដែលជាផលប្រយោជន៍រួម ពុំមែនជាផលប្រយោជន៍ផ្ទាល់ខ្លួននោះទេ។

# ឯកសារយោង

# ឯកសារយោង


**ច្បាប់/បទដ្ឋានគតិយុត្ត ជាតិ**

• រដ្ឋធម្មនុញ្ញប្រទេសចិន (Constitution of the People's Republic of China)

• ច្បាប់សញ្ញាតិរបស់រដ្ឋាភិបាលតៃវ៉ាន់ ដោយក្រសួងមហាផ្ទៃ ចុះថ្ងៃទី១៥ ខែ១២ ឆ្នាំ២០២១ (Taiwan Nationality Act, Category: Ministry of the Interior, Amended Date: 15/12/2021)

**ច្បាប់/បទដ្ឋានគតិយុត្ត អន្តរជាតិ**

• អនុសញ្ញា Montevideo Convention on the Rights and Duties of States

• កិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ស្តីពីការបញ្ឈប់អរិភាពនៅវៀតណាម ថ្ងៃទី២០ កក្កដា ឆ្នាំ១៩៥៤ (Geneva Agreements 20-21 July 1954, Agreement on the Cessation of Hostilities in Viet-Nam 20 July 1954)

• មហាសន្និបាតអង្គការសហប្រជាជាតិ លើកទី២៦ ស្តីពីការស្តារឡើងវិញនូវសិទ្ធិស្របច្បាប់នៃសាធារណរដ្ឋប្រជាមានិតចិននៅក្នុងអង្គការសហប្រជាជាតិ General Assemly-Tweety-sixth Session of Restoration of the lawful rights of the People's Republic of China in the United Nations

**អត្ថបទ/សៀវភៅ (ជាភាសាខ្មែរ)**

• ហ្សង់-ហ្វ្រង់ស័រ តាន់, មហាយក្សចិន ភូមិសាស្ត្រនយោបាយនៃប្រទេសចិន។

• ហ្សង់-ហ្វ្រង់ស័រ តាន់, ចម្បាំងត្រជាក់រវាងអាមេរិកនិងចិន ភូមិសាស្ត្រនយោបាយអាស៊ីអាគ្នេយ៍។

• អ៊ឹង រដ្ឋា, នីតិអន្តរជាតិសាធារណៈ Public International Law, បោះពុម្ពលើកទី៨ ឆ្នាំ២០១៨។

• ខៀវ ថវិកា, នីតិអន្តរជាតិសាធារណៈ Public International Law ភាគទី១, បោះពុម្ពនៅភ្នំពេញ ឆ្នាំ ២០១០។

• នួន សុធិមន្ត, នីតិអន្តរជាតិសាធារណៈ Public International Law។

• ខឿក ពិដោរ, មេរៀន នីតិសាធារណៈ ទ្រឹស្តី នីតិអន្តរជាតិសាធារណៈ, បោះពុម្ពលើកទី១ នៅឆ្នាំ ២០១១។

• មាស ប៉ូវ៉ា, នីតិអន្តរជាតិសាធារណៈ, បោះពុម្ព ឆ្នាំ២០១៣។

• ចាន់ ផារិទ្ធ, ទំនាក់ទំនងអន្តរជាតិ, បោះពុម្ព ឆ្នាំ២០១៥។

• អ៊ឹង រដ្ឋា, នីតិអន្តរជាតិសាធារណៈ, បោះពុម្ពលើកទី៦(ភ្នំពេញ, ២០១២)។

• ជុំ អ៊ីម, ទំនាក់ទំនងអន្តរជាតិ, បោះពុម្ពលើកទី២(ភ្នំពេញ ៖ រោងពុម្ពជោគជ័យ, ២០១១)។

• ខៀវ ថវិកា, នីតិអន្តរជាតិសាធារណៈ, បោះពុម្ពលើកទី១(ភ្នំពេញ ៖ គីម សួគ៍, ២០១០)។

**គេហទំព័រ (ស្ថាប័នជាតិ)**

- គេហទំព័រ ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតចិន (The State Council of the People's Republic of China) http://english.www.gov.cn/
- គេហទំព័រ មូលដ្ឋានទិន្នន័យច្បាប់ និងបទប្បញ្ញត្តិនៃសាធារណៈរដ្ឋចិន (Law & Regulations Database of The Republic of China) https://law.moj.gov.tw/ENG/Index.aspx
- គេហទំព័រ https://www.taiwan.gov.tw/index.php/
- គេហទំព័រ https://www.boca.gov.tw/mp-2.html

**គេហទំព័រ (ក្រៅពីស្ថាប័នជាតិ)**

- គេហទំព័រ UNIVERSITY OF OSLO https://www.uio.no/english/
- គេហទំព័រ https://blog.ipleaders.in/state-recognition/
- គេហទំព័រ https://vatican-city-tickets.com/km/
- គេហទំព័រ https://km.eferrit.com/
- គេហទំព័រ 1914-1918-Online https://encyclopedia.1914-1918-online.net/home/
- គេហទំព័រ Britannica https://www.britannica.com
- គេហទំព័រ United Nations Digital Library https://digitallibrary.un.org/?ln=en

**គេហទំព័រ (សារព័ត៌មានជាតិ និងអន្តរជាតិ)**

- ភ្នាក់ងារសារព័ត៌មាន Reuter https://www.reuters.com/
- គេហទំព័រសារព័ត៌មាន Fresh News https://www.freshnewsasia.com/index.php/en/
- គេហទំព័រសារព័ត៌មាន ដើមអម្ពិល https://dap-news.com
- គេហទំព័រសារព័ត៌មាន CNN Breaking News https://edition.cnn.com/world
- គេហទំព័រសារព័ត៌មាន The Weekend Australian https://www.theaustralian.com.au

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

១. រដ្ឋធម្មនុញ្ញប្រទេសចិន Constitution of the People’s Republic of China

២. អនុសញ្ញា ទីក្រុងម៉ុងតេវីឌេអូ ស្តីពី សិទ្ធិ និង ករណីកិច្ចរបស់រដ្ឋ

៣. កិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ (ថ្ងៃទី២០-២១ ខែកក្កដា ឆ្នាំ១៩៥៤)

៤. MOFA to release new version of e-passport as of January 11, 2021 (Press Release no. 283)

៥. មហាសន្និបាតអង្គការសហប្រជាជាតិ United Nations General Assembly Twenty-sixth session

# ឧបសម្ព័ន្ធទី១

# រដ្ឋធម្មនុញ្ញប្រទេសចិន

# Constitution of the People’s Republic of China

# ឧបសម្ព័ន្ធទី២

# អនុសញ្ញា ទីក្រុងម៉ុងតេវីដេអូ ស្ដីពី

# សិទ្ធិ និង ករណីកិច្ចរបស់រដ្ឋ

## Montevideo Convention on the Rights and Duties of States

**Signed at Montevideo, 26 December 1933**
**Entered into Force, 26 December 1934**
**Article 8 reaffirmed by Protocol, 23 December 1936**

Bolivia alone amongst the states represented at the Seventh International Conference of American States did not sign the Convention. The United States of America, Peru, and Brazil ratified the Convention with reservations directly attached to the document.

### CONVENTION ON RIGHTS AND DUTIES OF STATES

The Governments represented in the Seventh International Conference of American States:

Wishing to conclude a Convention on Rights and Duties of States, have appointed the following Plenipotentiaries:

Honduras:
Miguel PAZ Baraona
Augusto C. COELLO
Luis BOGRAN

United States of America:
Cordell HULL
Alexander W. WEDDELL
J. Reuben CLARK
J. Butler WRIGHT
Spruille BRADEN
Miss Sophonisba P. BRECKINRIDGE

El Salvador:
Hector David CASTRO
Arturo Ramon AVILA
J. Cipriano CASTRO

Dominican Republic:
Tulio M. CESTERO

Haiti:
Justin BARAU
Francis SALGADO
Antoine PIERRE-PAUL
Edmond MANGONES

Argentina:
Carlos SAAVEDRA Lamas
Juan F. CAFFERATA

Ramon S. CASTILLO
Carlos BREBBIA
Isidoro RUIZ Moreno
Luis A. PODESTA Costa
Raul PREBISCH
Daniel ANTOKOLETZ

Venezuela:
Cesar ZUMETA
Luis CHURTON
José Rafael MONTILLA

Uruguay:
Alberto MANE
Juan José AMEZAGA
José G. ANTUNA
Juan Carlos BLANCO
Senora Sofia A. V. DE DEMICHELI
Martin R. ECHEGOYEN
Luis Alberto DE HERRERA
Pedro MANINI Rios
Mateo MARQUES Castro
Rodolfo MEZZERA
Octavio MORATA
Luis MORQUIO
Teofilo PINEYRO Chain
Dardo REGULES
José SERRATO
José Pedro VARELA

Paraguay:
Justo Pastor BENITEZ
Geronimo RIART
Horacio A. FERNANDEZ
Senorita Maria F. GONZALEZ

Mexico:
José Manuel PUIG Casauranc
Alfonso REYES
Basilio VADILLO
Genaro V. VASQUEZ
Romeo ORTEGA
Manuel J. SIERRA
Eduardo SUAREZ

Panama:
J. D. AROSEMENA
Eduardo E. HOLGUIN
Oscar R. MULLER
Magin PONS

Bolivia:

Casto ROJAS
David ALVESTEGUI
Arturo PINTO Escalier

Guatemala:
Alfredo SKINNER Klee
José GONZALEZ Campo
Carlos SALAZAR
Manuel ARROYO

Brazil:
Afranio DE MELLO Franco
Lucillo A. DA CUNHA Bueno
Francisco Luis DA SILVA Campos
Gilberto AMADO
Carlos CHAGAS
Samuel RIBEIRO

Ecuador:
Augusto AGUIRRE Aparicio
Humberto ALBORNOZ
Antonio PARRA
Carlos PUIG Vilassar
Arturo SCARONE

Nicaragua:
Leonardo ARGUELLO
Manuel CORDERO Reyes
Carlos CUADRA Pasos

Colombia:
Alfonso LOPEZ
Raimundo RIVAS
José CAMACEO Carreno

Chile:
Miguel CRUCHAGA Tocornal
Octavio SENORET Silva
Gustavo RIVERA
José Ramon GUTIERREZ
Felix NIETO DEL RIO
Francisco FIGUEROA Sanchez
Benjamin COHEN

Peru:
Alfredo SOLE Y MURO
Felipe BARREDA Laos
Luis Fernan CISNEROS

Cuba:
Angel Alberto GIRAUDY
Herminio PORTELL Vila

Alfredo NOGUEIRA

Who, after having exhibited their Full Powers, which were found to be in good and due order, have agreed upon the following:

**Article 1**

The state as a person of international law should possess the following qualifications: (a) a permanent population; (b) a defined territory; (c) government; and (d) capacity to enter into relations with the other states.

**Article 2**

The federal state shall constitute a sole person in the eyes of international law.

**Article 3**

The political existence of the state is independent of recognition by the other states. Even before recognition the state has the right to defend its integrity and independence, to provide for its conservation and prosperity, and consequently to organize itself as it sees fit, to legislate upon its interests, administer its services, and to define the jurisdiction and competence of its courts.

The exercise of these rights has no other limitation than the exercise of the rights of other states according to international law.

**Article 4**

States are juridically equal, enjoy the same rights, and have equal capacity in their exercise. The rights of each one do not depend upon the power which it possesses to assure its exercise, but upon the simple fact of its existence as a person under international law.

**Article 5**

The fundamental rights of states are not susceptible of being affected in any manner whatsoever.

**Article 6**

The recognition of a state merely signifies that the state which recognizes it accepts the personality of the other with all the rights and duties determined by international law. Recognition is unconditional and irrevocable.

**Article 7**

The recognition of a state may be express or tacit. The latter results from any act which implies the intention of recognizing the new state.

**Article 8**

No state has the right to intervene in the internal or external affairs of another.

**Article 9**

The jurisdiction of states within the limits of national territory applies to all the inhabitants.

Nationals and foreigners are under the same protection of the law and the national authorities and the foreigners may not claim rights other or more extensive than those of the nationals.

**Article 10**

The primary interest of states is the conservation of peace. Differences of any nature which arise between them should be settled by recognized pacific methods.

**Article 11**

The contracting states definitely establish as the rule of their conduct the precise obligation not to recognize territorial acquisitions or special advantages which have been obtained by force whether this consists in the employment of arms, in threatening diplomatic representations, or in any other effective coercive measure. The territory of a state is inviolable and may not be the object of military occupation nor of other measures of force imposed by another state directly or indirectly or for any motive whatever even temporarily.

**Article 12**

The present Convention shall not affect obligations previously entered into by the High Contracting Parties by virtue of international agreements.

**Article 13**

The present Convention shall be ratified by the High Contracting Parties in conformity with their respective constitutional procedures. The Minister of Foreign Affairs of the Republic of Uruguay shall transmit authentic certified copies to the governments for the aforementioned purpose of ratification. The instrument of ratification shall be deposited in the archives of the Pan American Union in Washington, which shall notify the signatory governments of said deposit. Such notification shall be considered as an exchange of ratifications.

**Article 14**

The present Convention will enter into force between the High Contracting Parties in the order in which they deposit their respective ratifications.

**Article 15**

The present Convention shall remain in force indefinitely but may be denounced by means of one year's notice given to the Pan American Union, which shall transmit it to the other signatory governments. After the expiration of this period the Convention shall cease in its effects as regards the party which denounces but shall remain in effect for the remaining High Contracting Parties.

**Article 16**

The present Convention shall be open for the adherence and accession of the States which are not signatories. The corresponding instruments shall be deposited in the archives of the Pan American Union which shall communicate them to the other High Contracting Parties.

IN WITNESS WHEREOF, the following Plenipotentiaries have signed this Convention in Spanish, English, Portuguese and French and hereunto affix their respective seals in the city of Montevideo, Republic of Uruguay, this 26th day of December, 1933.

**Reservations**

The Delegation of the United States of America, in signing the Convention on the Rights and Duties of States, does so with the express reservation presented to the Plenary Session of the Conference on December 22, 1933, which reservation reads as follows:

The Delegation of the United States, in voting "yes" on the final vote on this committee recommendation and proposal, makes the same reservation to the eleven articles of the project or proposal that the United States Delegation made to the first ten articles during the final vote in the full Commission, which reservation is in words as follows:

> "The policy and attitude of the United States Government toward every important phase of international relationships in this hemisphere could scarcely be made more clear and definite than they have been made by both word and action especially since March 4. I [Secretary of State Cordell Hull, chairman of U.S. delegation] have no disposition therefore to indulge in any repetition or rehearsal of these acts and utterances and shall not do so. Every observing person must by this time thoroughly understand that under the Roosevelt Administration the United States Government is as much opposed as any other government to interference with the freedom, the sovereignty, or other internal affairs or processes of the governments of other nations.
>
> "In addition to numerous acts and utterances in connection with the carrying out of these doctrines and policies, President Roosevelt, during recent weeks, gave out a public statement expressing his disposition to open negotiations with the Cuban Government for the purpose of dealing with the treaty which has existed since1903. I feel safe in undertaking to say that under our support of the general principle of non-intervention as has been suggested, no government need fear any intervention on the part of the United States under the Roosevelt Administration. I think it unfortunate that during the brief period of this Conference there is apparently not time within which to prepare interpretations and definitions of these fundamental terms that are embraced in the report. Such definitions and interpretations would enable every government to proceed in a uniform way without any difference of opinion or of interpretations. I hope that at the earliest possible date such very important work will be done. In the meantime in case of differences of interpretations and also until they (the proposed doctrines and principles) can be worked out and codified for the common use of every government, I desire to say that the United States Government in all of its international associations and relationships and conduct will follow scrupulously the doctrines and policies which it has pursued since March 4 which are embodied in the different addresses of President Roosevelt since that time and in the recent peace address of myself on the 15th day of December before this Conference and in the law of nations as generally recognized and accepted".

The delegates of Brazil and Peru recorded the following private vote with regard to article 11: "That they accept the doctrine in principle but that they do not consider it codifiable because there are some countries which have not yet signed the Anti-War Pact of Rio de Janeiro 4 of which this doctrine is a part and therefore it does not yet constitute positive international law suitable for codification".

Honduras:
Miguel PAZ Baraona
Augusto C. COELLO
Luis BOGRAN

United States of America:
Alexander W. WEDDELL
J. Butler WRIGHT

El Salvador:

Hector David CASTRO
Arturo Ramon AVILA
Dominican Republic:
Tulio M. CESTERO

Haiti:
J. BARAU
F. SALGADO
Edmond MANGONES
A. PIERRE-PAUL

Argentina:
Carlos SAAVEDRA Lamas
Juan F. CAFFERATA
Ramon S. CASTILLO
I. RUIZ Moreno
L. A. PODESTA Costa
D. ANTOKOLETZ

Venezuela:
Luis CHURTON
J. R. MONTILLA

Uruguay:
A. MANE
José Pedro VARELA
Mateo MARQUES Castro
Dardo REGULES
Sofia Alvarez Vignoli DE DEMICHELI
Teofilo PINEYRO Chain
Luis A. DE HERRERA
Martin R. ECHEGOYEN
José G. ANTUNA
J. C. BLANCO
Pedro MANINI Rios
Rodolfo MEZZERA
Octavio MORATA
Luis MORQUIO
José SERRATO

Paraguay:
Justo Pastor BENITEZ
Maria F. GONZALEZ

Mexico:
B. VADILLO
M. J. SIERRA
Eduardo SUAREZ

Panama:
J. D. AROSEMENA
Magin PONS
Eduardo E. HOLGUIN
Guatemala:
M. ARROYO

Brazil:
Lucillo A. DA CUNHA Bueno
Gilberto AMADO

Ecuador:

A. AGUIRRE Aparicio
H. ALBORNOZ
Antonio PARRA V.
C. PUIG V.
Arturo SCARONE

Nicaragua:
Leonardo ARGUELLO
M. CORDERO Reyes
Carlos CUADRA Pasos

Colombia:
Alfonso LOPEZ
Raimundo RIVAS

Chile:
Miguel CRUCHAGA
J. Ramon GUTIERREZ
F. FIGUEROA
F. NIETO DEL RIO
B. COHEN

Peru:
(with reservation set forth)
Alfredo SOLE Y MURO

Cuba:
Alberto GIRAUDY
Herminio PORTELL Vila
Ing. NOGUEIRA

# ឧបសម្ព័ន្ធទី៣

## កិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ

(ថ្ងៃទី២០-២១ ខែកក្កដា ឆ្នាំ១៩៥៤)

# Geneva Agreements

# 20-21 July 1954

---

## Agreement on the Cessation of Hostilities in Viet-Nam

## 20 July 1954

**CHAPTER I**

**Provisional Military Demarcation Line and Demilitarized Zone**

**Article 1**

A provisional military demarcation line shall be fixed, on either side of which the forces of the two parties shall be regrouped after their withdrawal, the forces of the People's Army of Viet-Nam to the north of the line and the forces of the French Union to the south.

The provisional military demarcation line is fixed as shown on the map attached (see Map No. 1).

It is also agreed that a demilitarized zone shall be established on either side of the demarcation line, to a width of not more than 5 Kms. from it, to act as a buffer zone and avoid any incidents which might result in the resumption of hostilities.

**Article 2**

The period within which the movement of all the forces of either party into its regrouping zone on either side of the provisional military demarcation line shall be completed shall not exceed three hundred (300) days from the date of the present Agreement's entry into force.

**Article 3**

When the provisional military demarcation line coincides with a waterway, the waters of such waterway shall be open to civil navigation by both parties wherever one bank is controlled by one party and the other bank by the other party. The Joint Commission shall establish rules of navigation for the stretch of waterway in question. The merchant shipping and other civilian craft of each party shall have unrestricted access to the land under its military control.

**Article 4**

The provisional military demarcation line between the two final regrouping zones is extended into the territorial waters by a line perpendicular to the general line of the coast.

All coastal islands north of this boundary shall be evacuated by the armed forces of the French Union, and all islands south of it shall be evacuated by the forces of the People's Army of Viet-Nam.

**Article 5**

To avoid any incidents which might result in the resumption of hostilities, all military forces, supplies and equipment shall be withdrawn from the demilitarized zone within twenty-five (25) days of the present Agreement's entry into force.

**Article 6**

No person, military or civilian, shall be permitted to cross the provisional military demarcation line unless specifically authorized to do so by the Joint Commission.

**Article 7**

No person, military or civilian, shall be permitted to enter the demilitarized zone except persons concerned with the conduct of civil administration and relief and persons specifically authorized to enter by the Joint Commission.

**Article 8**

Civil administration and relief in the demilitarized zone on either side of the provisional military demarcation line shall be the responsibility of the Commanders-in-Chief of the two parties in their respective zones. The number of persons, military or civilian, from each side who are permitted to enter the demilitarized zone for the conduct of civil administration and relief shall be determined by the respective Commanders, but in no case shall the total number authorized by either side exceed at any one time a figure to be determined by the Trung Gia military Commission or by the Joint Commission. The number of civil police and the arms to be carried by them shall be determined by the Joint Commission. No one else shall carry arms unless specifically authorized to do so by the Joint Commission.

**Article 9**

Nothing contained in this chapter shall be construed as limiting the complete freedom of movement, into, out of or within the demilitarized zone, of the Joint Commission, its joint groups, the International Commission to be set up as indicated below, its inspection teams and any other persons, supplies or equipment specifically authorized to enter the demilitarized zone by the Joint Commission. Freedom of movement shall be permitted across the territory under the military control of either side over any road or waterway which has to be taken between points within the demilitarized zone when such points are not connected by roads or waterways lying completely within the demilitarized zone.

## CHAPTER II

### Principles and Procedure Governing Implementation of the Present Agreement

**Article 10**

